# មជ្ឈមណ្ឌលឯកសារកម្ពុជា

## សម្ភាសន៍ជាមួយ អ៊ីន ផន ភេទប្រុស អាយុ៦៤ឆ្នាំ

## មុខងារសម័យខ្មែរក្រហមៈ កងទ័ពកងពល១៦៤

## ស្រុកកំណើតនៅភូមិខ្នាចថោរ ឃុំគុស ស្រុកត្រាំកក់ ខេត្តតាកែវ

## រស់នៅភូមិត្រពាំងប្រាសាទ ឃុំត្រពាំងប្រាសាទ ស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ

## ថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៣

## សម្ភាសន៍ដោយៈ ឡុង ដានី

## ០១:២៧:២១

## ៣៦ទំព័រ

ដានីៈ ដំបូងខ្ញុំចង់ស្គាល់ឈ្មោះអ៊ំពេញ?

ផនៈ ខ្ញុំឈ្មោះ អ៊ីន ផន ។

ដានីៈ ផន?

ផនៈ បាទ! ផន ។

ដានីៈ អ៊ំអាយុប៉ុន្មានហើយសព្វថ្ងៃ?

ផនៈ ភា៦៤ឆ្នាំ ។

ដានីៈ អ៊ំឈ្មោះផន ហ្នឹងមានឈ្មោះអីក្រៅទៀត?

ផនៈ អត់មានទេ ។

ដានីៈ តាំងពីនេះមកឈ្មោះហ្នឹងរហូត?

ផនៈ ឈ្មោះអីចឹង ។

ដានីៈ កំណើតកើតជានៅភូមិ ឃុំអីដែរ?

ផនៈ នៅភូមិខ្នាចថោរ ឃុំគុស ស្រុកត្រាំកក់ ខេត្តតាកែវ ។

ដានីៈ អ៊ំឪពុកម្តាយអ៊ំគាត់ឈ្មោះអីដែរ?

ផនៈ ឪពុកស្លាប់អស់ហើយ ស្លាប់ទាំងពីរ ។

ដានីៈ ស្លាប់តាំងពីអង្កាល់?

ផនៈ ឪពុកស្លាប់តាំងពីខ្ញុំនៅតូចៗ ។

ដានីៈ គាត់ឈ្មោះអីទៅ?

ផនៈ ឪពុកឈ្មោះ ប៊ូ អ៊ីន ។ ខ្ញុំដាក់ឪពុកខ្ជិលដាក់តា ។

ដានីៈ គាត់ស្លាប់តាំងពីអ៊ំនៅតូច ។

ផនៈ បាទ! ស្លាប់តាំងពីនៅតូច ។

ជានី៖ ចុះម្ដាយ?

ជន៖ ម្ដាយ វង់ អោម ។

ជានី៖ សព្វថ្ងៃគាត់នៅរស់?

ជន៖ ស្លាប់ ។

ជានី៖ គាត់ស្លាប់តាំងពីអង្កាល់ទៅអ៊ំ?

ជន៖ ម្ដាយខ្ញុំស្លាប់អត់ដឹងដែរ ខ្ញុំនៅនេះ អាចស្លាប់ឆ្នាំ៩២តាមមើល ព្រោះអត់បានដឹង ។

ជានី៖ អត់ទាន់?

ជន៖ នៅនេះ ។ ឆ្នាំ៩២ ព្រោះខ្ញុំនៅនេះ ។

ជានី៖ យើងអត់ទាន់សមាហរណកម្ម ។

ជន៖ អត់បាននៅ ។

ជានី៖ អ៊ំបងប្អូនបង្កើតប៉ុន្មាននាក់ដែរ?

ជន៖ ខ្ញុំបងប្អូនបង្កើត៦នាក់ ។

ជានី៖ ៦នាក់ ប្រុសប៉ុន្មាន ស្រីប៉ុន្មានដែរ?

ជន៖ ស្រី៥ ប្រុសម្នាក់ឯង ។

ជានី៖ គាត់នៅទាំងអស់គ្នា៥នាក់?

ជន៖ បងស្លាប់អស់២ ស្លាប់បងស្រីអស់២ ។

ជានី៖ គាត់ស្លាប់ដោយជំងឺយើងចាស់ជរា?

ជន៖ ស្លាប់ដោយជំងឺ ។

ជានី៖ អ៊ំកូនទីប៉ុន្មានទៅ?

ជន៖ ខ្ញុំកូនទី៥ ។

ជានី៖ បន្ទាប់ពៅ?

ជន៖ បាទ! បន្ទាប់ពៅ ។

ជានី៖ អ៊ីចឹងកាលពីក្មេងៗអ៊ំបានរៀនសូត្រដល់ណាដែរ?

ជន៖ ខ្ញុំរៀនសូត្របានថ្នាក់ទី៩យើងសង្គមចាស់ ។

ជានី៖ នៅសាលា?

ជន៖ នៅសាលាវត្ត ។

ជានី៖ វត្ត?

ជន៖ វត្តនៅជិតផ្ទះ សាលាវត្តមុន្នីរង្សី រៀនសាលាវត្ត ។

ដានី: កាលហ្នឹងម៉េចបានអ៊ំរៀនបានត្រឹមថ្នាក់ទី៩?

ជនៈ និយាយរួមទៅវាក្រសាលា ហើយម្យ៉ាងខ្ញុំបើនិយាយវានិស្ស័យតាមមើល បានត្រឹមប៉ុណ្ណឹងឯង ។

ដានី: កាលពីក្មេង អ៊ំគិតថាចង់រៀនឲ្យបានច្រើន ចង់ធ្វើអី មានដែលធ្លាប់បានគិតអីចឹងទេ?

ជនៈ អត់បាន ។

ដានី: អត់ដែលគិតអីចឹង?

ជនៈ បាទ! រៀនបានប៉ុណ្ណឹងក៏ឈប់ ។

ដានី: ឈប់ដោយចិត្តឯង ឬដោយសារសំពាធពីក្រុមគ្រួសារ?

ជនៈ ទេ អត់មានសំពាធអីក្រុមគ្រួសារ និយាយរួមផ្សំគ្នាគិតទៅ ម្យ៉ាងមើលទៅកាលជំនាន់ហ្នឹងសាលាក៏វាឆ្ងាយ បើទៅពីហ្នឹងទៀតវាទៅឆ្ងាយ ខ្ញុំរៀនបានតែប៉ុណ្ណឹង ។

ដានី: អ៊ំអត់ដែលគិតថាចង់ធ្វើនេះ ធ្វើនោះ អត់ដែលបានគិត?

ជនៈ អត់ដែលគិត ។

ដានី: ឆ្នាំណាដែលអ៊ំឈប់ហ្នឹង?

ជនៈ ខ្ញុំឈប់ឆ្នាំ៦៧ ។

ដានី: មុនរដ្ឋប្រហារ?

ជនៈ មុន ។

ដានី: អ៊ំចូលបានប៉ុន្មានឆ្នាំរៀន ថ្នាក់ទីប៉ុន្មានបានដល់ថ្នាក់ទី៩?

ជនៈ ថ្នាក់ទី១២ជំនាន់នោះ ១២, ១១, ១០, ៩ ប៉ុណ្ណឹងឯង ។

ដានី: បាន៨ឆ្នាំ?

ជនៈ បាទ!

ដានី: ចូលឆ្នាំប៉ុន្មានទៅចូលរៀន?

ជនៈ បើនិយាយពីរៀនតិចៗដំបូង រៀនសាលាវត្ត ពីដើមទៅខាងខ្ញុំគេនិយមនៅវត្ត ល្មមៗគេបញ្ជូនឲ្យមកវត្ត ខ្ញុំនៅវត្តតាំងពីឆ្នាំ៥៨ ហើយខ្ញុំនៅបានអាយុ១៧ ។

ដានី: អ៊ំឈប់ពេលហ្នឹងអ៊ំអាយុ១៧?

ជនៈ បាទ! អាយុ១៧ ។

ដានី: ដល់ពេលអ៊ំឈប់ អ៊ំធ្វើអីវិញទៅ?

ជនៈ ឈប់ពីរៀន បួស ។

ដានី: បួសនៅវត្ត?

ជនៈ	បួសនៅវត្តជិតផ្ទះហ្នឹងឯង វត្តដែលរៀន ។

ដានីៈ	បួសបានប៉ុន្មានវស្សាទៅ?

ជនៈ	បួសបាន៥វស្សា ។

ដានីៈ	បានច្រើនដែរ? ពីឆ្នាំ៦៧-៧២ ។ អីចឹងពេលដែលរដ្ឋប្រហារហើយក៏អំនៅបួសដែរ?

ជនៈ	នៅ ។

ដានីៈ	គេអត់ទាន់ដូចថា ពេលហ្នឹងយើងមានសង្គ្រាមច្របូកច្របល់?

អ្នកជិតខាងៈ បួសទាល់តែគេរំលាយចោល ។

ដានីៈ	ឆ្នាំ៧២ហ្នឹងយ៉ាងម៉េចទៅអ៊ំ បានសឹកវិញ?

ជនៈ	អត់ទាន់អី ឆ្នាំ៧២នៅនេះទេ អត់ទាន់អីទេ ឆ្នាំ៧២នៅមានវត្ត ខ្ញុំកាលហ្នឹងឆ្នាំ៧២ក៏ខ្ញុំសឹកមកវិញ ។ បួសពីអាយុ១៧ ឆ្នាំ៦៧ខ្ញុំបួស ឆ្នាំ៧២ខ្ញុំសឹកវិញ កាលហ្នឹងវត្តអត់ទាន់មានអីទេ ។

ដានីៈ	កាលហ្នឹងពេលយើងបួសយើងមានរៀនអីខាងធម៌វិន័យបានច្រើនទេ?

ជនៈ	រៀនបានល្មមគ្រាន់តែនេះឯង ហើយម្យ៉ាងខ្ញុំក៏ជួយការងារសង្គមដែរ ខ្ញុំជួយបង្រៀនក្មេង

ដានីៈ	ពេលហ្នឹងដូចថាព្រះសង្ឃយើងអាចបង្រៀនតាមក្របខណ្ឌ ឥឡូវហ្នឹងគេឆ្លងកាត់ការិយាល័យអប់រំ មន្ទីរអប់រំ កាលពីមុនមកអីចឹងដែលអត់ ព្រះសង្ឃបង្រៀន?

ជនៈ	ពីមុនអត់ដូចឥឡូវតាមមើល ព្រោះខ្ញុំកាលហ្នឹង ខ្ញុំបង្រៀនដូចជួយគ្នា ដូចឃើញលោកណាមានចំណេះឲ្យជួយបង្រៀនក្មេងៗ រៀនថ្នាក់ទី១២ទេជំនាន់នោះ ក្មេងតូចៗ ។

ដានីៈ	កាលហ្នឹងលោកគ្រូសង្ឃរាជអី ព្រះអង្គចេះដឹងជ្រៅជ្រះដែរ?

ជនៈ	ហ្នឹងហើយលោកជ្រៅជ្រះដែរ លោកគ្រូ ។

ដានីៈ	គាត់ព្រះនាមអីដែរ?

ជនៈ	ហើយលោកធ្លាប់ធ្វើគ្រូបង្រៀនដែរកាលជំនាន់នោះ លោកបង្រៀនក្មេងដែរដល់លោកចាស់ទៅជាប់ការងារកសាងវត្តអីចឹងទៅ ឲ្យខ្ញុំជំនួសឈ្មោះលោក ។

ដានីៈ	ឈ្មោះអីទៅ?

ជនៈ	ចៅអធិការលោកសុគតបាត់ឈ្មោះ មិន ខ្មែម ។

ដានីៈ	និន ខ្មែម?

ជនៈ	បាទ!

ដានីៈ	ច្រើនអង្គដែរនៅវត្តហ្នឹងពេលបួស?

ជនៈ	វត្តហ្នឹងវាអត់ទៀងដែរ ជួនកាល១០ទៅ ជួនកាលលើសពីទៅ ។

ដានី៖ ដល់ឆ្នាំ៧២ អ៊ំសឹក នេះយើងសឹកដោយខ្លួនឯងទេ ឬពេលហ្នឹងគេត្រូវ?

ជន៖ អត់ទេ អត់មានអ្នកណានេះអីទេ ខ្ញុំសឹក ។

ដានី៖ សឹកខ្លួនឯង?

ជន៖ បាទ!

ដានី៖ យ៉ាងម៉េចបានពេលហ្នឹងអ៊ំសឹក?

ជន៖ មើលឃើញសភាពការណ៍ដូចថាវា ឪពុកខ្ញុំ ដល់យើងនេះទៅ ចេះតែស្តាប់ មើលទៅសភាពការណ៍ដូចថាមិនយុទ្ធសាស្រ្តអីទៅទៀត ក៏ខ្ញុំសឹកទៅ នឹកឃើញថាវាមិនអាចតាមមើល ។

ដានី៖ សឹកមកអ៊ំមកធ្វើអីវិញទៅ?

ជន៖ សឹកមកចូលកងទ័ពបណ្តោយ ។

ដានី៖ សឹកមកចូលកងទ័ព?

ជន៖ បាទ!

ដានី៖ អត់បានមកអ្នកផ្ទះទេ?

ជន៖ បាននៅនេះដែរ បើនៅបានជួយធ្វើនេះមួយរដូវដែរ ។

ដានី៖ បានមកផ្ទះ បានមកជួយធ្វើស្រែមួយរដូវដែរ?

ជន៖ បាទ! បានមួយរដូវ ។

ដានី៖ ចូលកងទ័ពអ៊ំស្ម័គ្រចិត្ត ឬក៏មានចលនាអីយ៉ាងម៉េច យើងត្រូវតែមានការបង្ខិតបង្ខំឲ្យយើងចូល?

ជន៖ កាលនោះដូចថាវា អត់មានអ្នកណានេះទេ កាលហ្នឹងដូចថាយើងឃើញគេឃើញឯងទៅជិតនាន់នោះ ។

ដានី៖ ក៏ចូលកងទ័ព?

ជន៖ ហ្នឹងហើយ ។

ដានី៖ ឆ្នាំ៧២ដដែល?

ជន៖ ឆ្នាំ៧២ដដែល ។

ដានី៖ ដល់ពេលចូលកងទ័ពអ៊ំទៅនៅណាវិញទៅ?

ជន៖ ចូលកងទ័ពនៅតែម្តុំជុំវិញតាកែវហ្នឹងឯង ។

ដានី៖ ខាងជុំគិរី តាកែវ ខាងព្រៃដែន?

ជន៖ អត់ទេ នៅម្តុំលិចតាកែវ ពីខាងត្បូងតាកែវ នៅវិលជុំវិញតាកែវហ្នឹងឯង ។

ដានី: ចូលទៅបើតាមក្បួនខ្មាតយើងចូលទៅត្រូវទៅហាត់ក្បួនយុទ្ធសាស្ត្រកងទ័ព?

ជន: ហាត់ដែរ ហាត់នៅកន្លែងខ្លះទៅ អត់មានហាត់នៅមន្ទីរ ហាត់នៅតាមកន្លែង ។

ដានី: នៅកងណាទៅកាលហ្នឹង?

ជន: នៅកងតំបន់១៣ ។

ដានី: កាលហ្នឹងតំបន់គេហៅជាលេខ?

ជន: បាទ! លេខ តាកែវហ្នឹងតំបន់១៣ ។

ដានី: ក្នុងកងទ័ពតំបន់១៣?

ជន: បាទ!

ដានី: តែកាលហ្នឹងយើងដើរនៅតាមព្រំដែន ឬដើរជាមួយខាងពួកទាហាន?

ជន: ពួកទាហាន ។

ដានី: ពួកទាហាន?

ជន: ពួកទាហានលន់ នល់ ។

ដានី: លន់ នល់ គេនៅតាកែវ?

ជន: បាទ! ទាហាននៅតាកែវ និយាយរួមនៅគ្រប់កន្លែង ពួកខ្ញុំនៅភូមិ ភូមិជនបទទេ ។

ដានី: ដើរយូរដែលអត់កាលហ្នឹង?

ជន: ដើរយូរ ដើរទាល់តែ ។

ដានី: អ៊ំនៅខាងគិរីវង្សនៅខាងតាកែវហ្នឹងរហូតដល់បែកឆ្នាំ៧៥ ឬមានផ្លាស់ទៅណាទៀត?

ជន: មកទៀត ចេញពីហ្នឹងមក មកនៅផ្លូវជាតិលេខ៤ ។

ដានី: មកនៅផ្លូវជាតិលេខ៤ យើងនៅក្នុងកងពលវិញ?

ជន: បាទ!

ដានី: ហ្នឹងចេញពីតំបន់មក?

ជន: ចេញពីតំបន់ ។

ដានី: នៅកងពលណាទៅ?

ជន: កងពល ចង់ភ្លេចអស់ខ្លះ ដល់វែងឆ្ងាយពេកអត់បានគិតដល់ ។

ដានី: ដល់ពេលយើងដើរមកដល់ផ្លូវជាតិលេខ៤ ដើរទៅខាងណាវិញ?

ជន: ដើរពីខាងលិច ។

ដានី: ដើរពីខាងលិចចូល?

ជន: តាមផ្លូវលេខ៤ ម្តុំអង្គស្នួល ។

ដានីៈ អ្នកស្អួលចូលមកភ្នំពេញ?

ជនៈ អត់បានចូលដល់ទេ ខ្ញុំនៅត្រឹមកំបូល នៅខាងលិចកំបូល ដល់គេជ័យជំនះ១៧ មេសាទៅ

ដានីៈ ពីណាគេប្រធានកងពលកាលហ្នឹង?

ជនៈ ប្រធានកងពលកាលហ្នឹង ប្រធានកងពលនៅផ្លូវលេខ៤ ដូចតាមុត ចេះ វាច្រើនអត់សូវនេះដែរ ដូចថាយើងនៅហ្នឹងដែរ ទាហាននៅក្មេងៗ ក្រោមៗ ដល់អីចឹងអត់សូវចាប់អារម្មណ៍ ។

ដានីៈ អ៊ំកាលនៅខាងគិរីវង្ស ពីណាគេអ្នកប្រធាន?

ជនៈ ប្រធានហ្នឹង ប្រធានកាលហ្នឹងស្លាប់អស់ហើយគិតទៅ ម្នាក់នោះកាលហ្នឹងគេចូលមកទាហាននៅតាកែវ ក្រោយមកអត់ដែលបានជួបគ្នាទេ អត់ដឹងអ្នកណានៅ អ្នកណាអី ឥឡូវហ្នឹងក៏អត់ដឹងដែរ ។

ដានីៈ ដល់យើងវ៉ៃរំដោះបានទីក្រុងភ្នំពេញឆ្នាំ៧៥ យ៉ាងម៉េចទៀតទៅ? អ៊ំទៅនៅណាវិញ?

ជនៈ ៧៥ខ្ញុំទៅនៅខាងកំពង់សោម ។

ដានីៈ ទៅនៅខាងកំពង់សោមវិញ?

ជនៈ បាទ!

ដានីៈ ទៅនៅធ្វើអីវិញនៅខាងកំពង់សោម?

ជនៈ ទៅនៅកងទ័ពជដែល ទៅនៅខាងជើងទឹក ។

ដានីៈ នៅកងទ័ពជើងទឹក?

ជនៈ បាទ!

ដានីៈ នៅកងទ័ពជើងទឹកកាលហ្នឹងកងពលលេខប៉ុន្មានទៅ?

ជនៈ កងពល១៦៤ ។

ដានីៈ កងពល១៦៤ គេដូរលេខនេះ?

ជនៈ បាទ!

ដានីៈ អ៊ំនៅម្តុំណាកាលនៅ?

ជនៈ ខ្ញុំនៅកោះ ។

ដានីៈ នៅកោះតែម្តង?

ជនៈ កោះពូលូវៃ ។

ដានីៈ អ៊ំនៅខាងហ្នឹងខ្ញុំចង់ដឹងបន្តិច ឆ្នាំ៧៥ យើងមានវ៉ៃជាមួយកងទ័ពខាងយួនទេ?

ជនៈ បាទ!

ដានី:	ខាងកោះអី ដូចកោះមួយចំនួន កោះត្រល់, កោះពូលូវៃហ្នឹងមានវៃដែរ ?

ផន:	មាន តែខ្ញុំអត់មាន ព្រោះខ្ញុំកាលហ្នឹងខ្ញុំគ្រុនខ្ញុំមកសំរាកពេទ្យយូរមែនទែន ខ្ញុំសំរាកពេទ្យនៅកំពង់សោម ពេលគេវៃហ្នឹងខ្ញុំអត់ដឹងទេ ព្រោះខ្ញុំទៅក្រោយ ដល់យើងបានវិញបានខ្ញុំទៅនៅហ្នឹង បានខ្ញុំទៅ ។

ដានី:	ខាងកោះត្រល់អីដឹងទេ?

ផន:	អត់ទេ អត់បានដឹង ។

ដានី:	កាលហ្នឹងយើងវៃដែរ មានប្រទូស្តប្រត្រាស់គ្នា ហើយដូចខាងដើង ដល់ពេលវៃទៅគេចាប់បាន មានអីចឹងមែន?

ផន:	មិនដឹងយ៉ាងម៉េចទេកាលហ្នឹង ព្រោះខ្ញុំនៅគោកនេះដែរ អត់សូវបានដឹង ។ ខ្ញុំកាលហ្នឹងវាគ្រុនឡើង៨ខែ ។

ដានី:	គ្រុន៨ខែ?

ផន:	បាទ! មកនៅដេកពេទ្យនៅកំពង់សោម គ្រុនៗស្មានមិនរស់ផង គ្រុនចាញ់ ។

ដានី:	អីចឹងពេលដែលយើងឆ្នាំ៧៥ហើយ អ៊ំទៅនៅកោះភ្លាម?

ផន:	បាទ! គ្រាន់តែរំដោះភ្នំពេញហើយ ខ្ញុំទៅហ្នឹងបណ្តោយ ។ អត់បានចូលភ្នំពេញទេ ចេញពីកំបូលទៅនោះបណ្តោយ ។

ដានី:	ទៅកោះបានរយៈពេលប៉ុន្មានបានគ្រុនចាញ់?

ផន:	ទៅបានតែប៉ុន្មានខែ កាលហ្នឹង ទៅបានតិចដែរ ខែវស្សាទៅហ្នឹងវាភ្លៀងជោគជាំនៅកោះហើយយើងមិនធ្លាប់ ។

ដានី:	កាលហ្នឹងគេមានបញ្ហាជាមួយអាមេរិកាំងនៅខាងកោះតាង រឿងចាប់កប៉ាល់ម៉ាយ៉ាគេលហើយពួកអាមេរិកាំងមកទម្លាក់គ្រាប់បែក?

ផន:	ទម្លាក់គ្រាប់បែកដឹង ខ្ញុំដឹងថាគេទម្លាក់នៅកំពង់ផែ បើនោះអត់ដឹងទេ ព្រោះអត់ទាន់ ។

ដានី:	ទម្លាក់ខ្លាំងដែរ?

ផន:	ទម្លាក់ខ្លាំងដែរ ទម្លាក់នៅកំពង់ផែ គ្រាន់តែវាមិនត្រូវផែ វាត្រូវតែឃ្លាំងអង្ករ នៅមាត់ទឹកហ្នឹង ។

ដានី:	បានឃើញកប៉ាល់ម៉ាយ៉ាគេលហ្នឹង?

ផន:	អត់បានឃើញ ។

ដានី:	កាលគេទម្លាក់ហ្នឹងអ៊ំនៅណាកាលហ្នឹង?

ផនៈ ទម្លាក់ហ្នឹងដូចជាខ្ញុំនៅម្តុំនេះទេ ព្រោះកាលហ្នឹងគ្រាន់តែទម្លាក់រួច គេហៅកំលាំងយកទៅជួយពន្លត់ភ្លើងវាឆេះឃ្លាំង ខ្ញុំអាចដូចជានៅម្តុំ នៅខាងចំណោទរាម ខ្ញុំអត់ចាំ ចង់ភ្លេចបាត់យូរដែរ ។ ខ្ញុំនៅខាងម្តុំជិតមន្ទីរពេទ្យគេហៅកន្លែងគោ ។

ដានីៈ កន្លែងគោ២?

ផនៈ ហ្នឹងហើយគោ២ជិតមាត់ ។

ដានីៈ ជិតឆ្នេរអូរឈើទាល ។

ផនៈ ហ្នឹងហើយ ខ្ញុំនៅហ្នឹង ។

ដានីៈ ហ្នឹងកន្លែងអីគេ?

ផនៈ កន្លែងហ្នឹងគេបេះតែដាក់ពង្រាយនៅតាមកង គេបែកគ្នានៅ ។

ដានីៈ មិនមែនកន្លែងមន្ទីរកងពលទេ?

ផនៈ អត់ទេ មន្ទីរកងពលមួយសារហ្នឹងក៏អត់បានដឹងដែរ ។

ដានីៈ មន្ទីរពេទ្យនៅម្តុំណាទៅ?

ផនៈ មន្ទីរពេទ្យមួយខ្ពស់ ហ្នឹងមិនដឹងជាមន្ទីរតាំងពីដើម ឬគេគ្រាន់តែដាក់ទេ ហើយក្រោយមកក៏រាយតាមផ្ទះតូចៗនៅតាមមាត់ទឹក ។

ដានីៈ នៅតាមមាត់ទឹកវិញ?

ផនៈ សំរាប់អ្នកជំងឺ ។

ដានីៈ អ៊ំឈឺគ្រុនចាញ់ហ្នឹងគេ ពេទ្យគេមើលយ៉ាងម៉េចដែរ? បានអ៊ំនៅបានយូរម៉្លេះរហូតជិត១ឆ្នាំ?

ផនៈ វានេះ គ្រុនហ្នឹងបើនិយាយរួមចូលគ្រុនរ៉ាំរ៉ៃ គ្រុនបាន១-២ថ្ងៃជា អត់បានចេញមកកើតជាសុំគេចេញចាប់ផ្តើមគ្រុនទៀត គ្រុនញាក់ ដល់ហើយពេទ្យហ្នឹងគេថាបើគ្រុនហ្នឹង វាមានអ្នកនៅជិតហ្នឹងដែរ អ្នកទៅនៅពេទ្យ ចង់ឲ្យខ្ញុំទៅឆ្លុះមើល គេថាខ្ញុំធ្លាក់អណ្តើក អីចឹងបានវាគ្រុនរ៉ាំរ៉ៃ ។

ដានីៈ ព្រោះកាលហ្នឹងយើងមិនទាន់មានថ្នាំអីពូកែដូចឥឡូវ?

ផនៈ មិនទាន់មានថ្នាំពូកែដូចឥឡូវទេជំនាន់នោះ ថ្នាំធ្វើខ្លួនឯង ។

ដានីៈ ដល់ពេលជាបានត្រឡប់ទៅនៅកោះវិញ?

ផនៈ បាទ! ជាត្រឡប់ ។

ដានីៈ កោះពូលូវៃឆ្ងាយ?

ផនៈ ឆ្ងាយដែលហ្នឹង ។

ដានី៖ ជិះទៅប៉ុន្មានម៉ោងទៅ?

ជន៖ ជិះទៅ៥ - ៦ម៉ោង ។

ដានី៖ កប៉ាល់លឿនយើងជិះទៅ?

ជន៖ អត់លឿនទេ កាលនោះយើងអត់មានអាលឿនៗទេ មានតែកប៉ាល់យើងធន់ល្មមៗ ជិះលឿនដែរ ។

ដានី៖ ឈរជើងនៅកោះពូលូវៃភ្នាច្រើនទេ ប្រហែលប៉ុន្មាន?

ជន៖ មួយកងវរសេនាតូច ។

ដានី៖ កងវរសេនាតូចនៅលើកោះហ្នឹង?

ជន៖ បាទ!

ដានី៖ ពីណាគេដូចថាកាន់កងវរសេនាតូចហ្នឹង?

ជន៖ មិនដឹងឈ្មោះអី វរសេនាតូចកាលហ្នឹងគេមាន ផ្លាស់ប្តូរគ្នារហូតៗ តែខ្ញុំនៅសារក្រោយឈ្មោះ បាន កាន់កងទ័ព ។

ដានី៖ វរសេនាធំគេនៅណាវិញ?

ជន៖ នៅកោះតាង ។

ដានី៖ វរសេនាធំទៅឈរខាងកោះតាងវិញ?

ជន៖ បាទ! មកនៅជិតគោកនេះវិញ អានោះវាហួសកោះតាងទៅឆ្ងាយ ។

ដានី៖ វរសេនាធំលេខប៉ុន្មានកាលហ្នឹង?

ជន៖ វរសេនាធំកាលហ្នឹង៦២ ។

ដានី៖ កាលហ្នឹងវាមាន?

ជន៖ ៦១, ៦២, ៦៣ ។

ដានី៖ ៦១, ៦២, ៦៣ តែអ៊ំនៅក្នុងវរសេនាធំ៦២?

ជន៖ ៦២ ។

ដានី៖ ពីណាគេវរសេនាធំ?

ជន៖ វរសេនាធំ៦២កាលហ្នឹងឈ្មោះអីទេ ដូចឈ្មោះ មៀច ដូចថាវាមិននៅនឹង ដូនកាលយើងផ្លាស់ប្តូរៗ ។

ដានី៖ តាមុត គាត់ទៅខាងសមុទ្រដែរ?

ជន៖ តាមុត នៅហ្នឹងឯងខាងសមុទ្រ គាត់ប្រធានកងពល ។

ដានី៖ គាត់ប្រធានកងពល តែគាត់ចុះទៅតាមកោះដែលអត់?

ជនៈ គាត់អត់ទៅទេ គាត់នៅមើលកងទ័ព ។

ជានីៈ គាត់មានអនុៗគាត់ចាំនៅខាងកោះហ្នឹងដែល?

ជនៈ អត់ទេ ។ មានកងវរសេនាតូចនៅ ។

ជានីៈ ពីណាគេអនុគាត់ខ្លះ?

ជនៈ អត់ចាំទេខ្ញុំ ដឹងច្បាស់តែមេជាងគេ ឧស្សាហ៍ឃើញមុខ ក្រៅពីហ្នឹងមិនសូវទេ ។

ជានីៈ អ៊ំនៅកោះហ្នឹងរហូតដល់នេះ ឬមានផ្លាស់ទៅណា?

ជនៈ បើនិយាយពីនេះកងទ័ពមិនសូវបាននឹងប៉ុន្មានទេ តិចទៅនេះ តិចទៅនោះរហូត ។

ជានីៈ ទៅណាដែលអ៊ំ ចេញពីកោះពូលូវៃទៅណាទៀត?

ជនៈ មកខាងយើងកាលហ្នឹងគេហៅបូព៌ា មកខាងកំពង់ចាម ។

ជានីៈ ខាងកំពង់ចាម ខាងម្តុំណា?

ជនៈ ជិតនាន់ហ្នឹងយួនវៃតាមព្រំដែនហើយ ខ្ញុំនៅម្តុំ ទឹកដីវាអត់សូវចាំទៀត ខ្ញុំនៅម្តុំស្រុកដូចមេមត់ ខ្ញុំអត់សូវចាំទេ ។

ជានីៈ មេមត់ ក្រែក?

ជនៈ ខ្ញុំនៅតែមុខៗ ។

ជានីៈ អ៊ំដកចេញពីខាងកងពល១៦៤ នៅខាងកំពង់សោម មកខាងវៃយួននៅខាងបូព៌ា នៅខាងមេមត់?

ជនៈ បាទ! មិនប្រាកដថាមេមត់ ព្រោះខ្ញុំភ្លេចដែរ ខ្ញុំអត់ចាំ ។

ជានីៈ កងពលណាទៅកាលហ្នឹងមកហ្នឹងវិញ?

ជនៈ នៅកងពល៦០៣ ។

ជានីៈ ៦០៣របស់កូនប្រសារតាម៉ុក?

ជនៈ ហ្នឹងហើយ ។

ជានីៈ ឈ្មោះតា?

ជនៈ តាវិន ស្លាប់បាត់ហើយតាហ្នឹង ។

ជានីៈ ហេតុអីបានជាគេដកពីខាងកំពង់សោមហើយមកនេះវិញ? មកចូលហ្នឹងវិញ?

ជនៈ កំលាំងកងទ័ព សភាពការណ៍ខាងនោះអត់មានអី បានគេដកយកមក ។

ជានីៈ ដកមកច្រើនដែរ?

ជនៈ មកជារយៈ ។

ជានីៈ ចិតប៉ុន្មានដែលអ៊ំមក?

ជនៈ ៧៨ មកបានបន្តិច ខ្ញុំមកបានបន្តិច ។

ដានីៈ តាវិន គេដកមកពីណាដែលបានមកហ្នឹង ។

ជនៈ មិនដឹងនៅកន្លែណាពីដើមខ្ញុំអត់ស្គាល់ដែល ខ្ញុំមកជួបគ្នានៅហ្នឹង ពីមុនខ្ញុំអត់ដឹងដែរ មិនដឹងនៅណា វាផ្សេងៗគ្នា គេដកពីនោះៗមក ។

ដានីៈ កាលហ្នឹងតាបាវ គាត់នៅហ្នឹងដែរ?

ជនៈ តាបាវ យើងអន្លង់វែង?

ដានីៈ បាទ!

ជនៈ តាបាវ នៅហ្នឹងដែរ នៅ៦០៣ដូចគ្នា តែនៅវរសេនាធំផ្សេង ។

ដានីៈ គាត់នៅវរសេនាធំផ្សេង?

ជនៈ បាទ! ។

ដានីៈ ខ្ញុំជួបគាត់ គាត់ថាអីចឹងដែរ គាត់មកពីខាងតាកែវ គាត់មកនៅ ។

ជនៈ បាទ!

ដានីៈ កាលទៅវៃនៅខាងកំពង់ចាមយ៉ាងម៉េចដែរ ស្ថានភាពពេលហ្នឹង?

ជនៈ ស្ថានភាពពេលហ្នឹងបើខ្ញុំពិនិត្យ ខ្ញុំនិយាយរួមខ្ញុំចូលទៅវានេះរហូត មិនដែលវៃ ក្រោយពេលហ្នឹងសភាពការណ៍វាប្រែប្រួលខ្លាំងហើយ ទាំងប្រជាជន អីចឹងវាមានការលំបាកដែរ មិនបានប៉ុន្មាន មិនបានវៃធំដុំ ៧៩ក៏ខ្ញុំ ធម្មតាវារលាយអស់ហើយ ។

ដានីៈ កាលអ៊ំទៅ កាលទៅបូព៌ាហ្នឹង ទៅមុន សោ ភឹម គាត់សម្លាប់ខ្លួន ឬទៅ?

ជនៈ ដូចក្រោយទេ កាលហ្នឹងដូចអត់លឺសូរនិយាយអី ។

ដានីៈ អត់មានលឺសូរនិយាយរឿង សោ ភឹម អីទេ?

ជនៈ បាទ!

ដានីៈ ពីណាគេមកគ្រប់គ្រងនៅខាងបូព៌ាវិញ?

ជនៈ អត់ចាំទេ ដឹងតែអន្តភាពដែលនៅហ្នឹង ជាទូទៅអត់សូវដឹង អត់សូវយល់ ។

ដានីៈ អ៊ំដូចថាពេលហ្នឹង ដូចថាទៅបូព៌ាហើយយ៉ាងម៉េចទៀត? យួនចូលហើយផ្លាស់ប្តូរយ៉ាងម៉េច? ពេលយួនចូលប្រែប្រួលយ៉ាងម៉េច?

ជនៈ យួនចូលហើយក៏មកដកចេញពីមុខ មកតាមមូលដ្ឋានវិញមក មកបានតិចដែលទេ របៀបដូចថាមកហើយបេះតែមកបន្តៗរហូត មកព្រំដែន ។

ដានីៈ ពេលដែលយួនចូលហើយ យើងដកពីត្រឹមណាមកនៅណា? ហើយយ៉ាងម៉េចតមកដល់ណាទៀត?

ជនៈ ដកមកអត់សូវចាំដែរ ព្រោះតំបន់យើងអត់ធ្លាប់នេះ នៅបានតិចៗយើងចេះតែថយអីចឹងៗមករហូត របៀបដូចស្នាក់១-២ថ្ងៃយើងមកបន្តទៀត ។

ដានីៈ មកទាំងអស់កងពលទាំងអស់មក?

ជនៈ បាទ! តែវាមានបែកបាក់គ្នា មិនបាននៅទាំងអស់ មកទៅបងប្អូនខ្លះក៏នៅផ្ទះ ផ្ទះគេជិតហ្នឹងក៏គេទៅផ្ទះខ្លួនឯង ។

ដានីៈ អីចឹងក្នុងកងពលហ្នឹងចំរុះ? សមាសភាពមានអ្នកមកពីខាងតាកែវ, កំពង់ចាម, កំពង់ធំ?

ជនៈ ហ្នឹងហើយ កំពត មានចំរុះគ្នា ដល់ពេលអីចឹងគេអ្នកខាងកំពង់ចាមគេមកភូមិវិញដល់ផ្ទះហើយទៅវិញគ្មានអ្នកណាហាមឃាត់អីទេ គេទៅៗ ។

ដានីៈ ដល់ពេលអ៊ំចេះតែមកបន្តៗ?

ជនៈ បាទ!

ដានីៈ មកបន្តដល់ណាទៅ?

ជនៈ មករហូត និយាយរួមមកដល់មាត់ទន្លេហ្នឹងបានឆ្លងមកខាងលិចទន្លេ ។

ដានីៈ ទន្លេបិទ?

ជនៈ នៅម្តុំខាងក្រូចឆ្មារ ។

ដានីៈ ខាងក្រូចឆ្មារ!

ជនៈ ខ្ញុំឆ្លងតាមហ្នឹងឯង ខ្ញុំឆ្លងតាមហ្នឹងឯង ខ្ញុំឆ្លងមកស្ទឹងត្រង់ ។

ដានីៈ ឆ្លងមកស្ទឹងត្រង់ ខ្ញុំអ្នកស្រុកនៅខាងហ្នឹងដែរ ។

ជនៈ អីចឹង?

ដានីៈ បាទ! ហើយអ៊ំឆ្លងមកស្ទឹងត្រង់យើងកាត់មកតាមណាទៀត?

ជនៈ យើងមកនេះ មកពីហ្នឹងមកចេះតែមកតាមនេះរហូតដល់កំពង់ធំ ។

ដានីៈ មកជាមួយតាវិន ដែរ អត់ទេ?

ជនៈ តាវិន ហ្នឹងហើយមកជាមួយគ្នា ។

ដានីៈ ដល់ពេលបែកបាក់ទៅ កងទ័ពសល់ប៉ុន្មានទៅដែលមកដំណាលអ៊ំ ឆ្លងមកខាងស្ទឹងត្រង់ មកកំពង់ធំ?

ជនៈ កាលហ្នឹងមកគ្នាតិចដែរ មកជាមួយខ្ញុំ ដែលខ្ញុំនិយាយថា មកពីបូព៌ា មកឆ្លងទន្លេហ្នឹងគ្នាតិចដែលហើយ តែវាអត់បានចាំថាប៉ុន្មានៗ ភាគច្រើនក្មេងៗចេះតែជួយយកវាមក អ្នកខ្លះដែលផ្ទះវានៅឆ្ងាយ ចេះតែមកជាប់ជាមួយគ្នា ។

ដានីៈ ចេញពីហ្នឹងមកណាទៀតទៅ ពីកំពង់ធំ?

ជនៈ ចេញពីកំពង់ធំមកហ្នឹង មកព្រំដែន។

ដានីៈ ព្រំដែននៅម្តុំណាទៅ?

ជនៈ នៅយើងតាមនេះ ម្តុំទំនប់ដាច់។

ដានីៈ អីចឹងចេញពីកំពង់ធំ ដល់ឆ្នាំណាមកដល់ទំនប់ដាច់?

ជនៈ មកដល់ត្រឹមណាទេ ឆ្នាំប៉ុន្មានទេ ដូចជាមិនចាំ អត់ចាំទៀត។

ដានីៈ ដល់ពេលយ៉ាងម៉េចទៅ ដូចតាវិន គាត់នៅហ្នឹងរហូត ឬមានអីក្រោយមកមានការផ្លាស់ប្តូរអីយ៉ាងម៉េចដែរ កងពល?

ជនៈ ខ្ញុំមកបែកគ្នាទៀតដល់ពេលខ្ញុំមក និយាយរួមទៅខ្ញុំមកពីនោះបែកគ្នា មកនៅកន្លែងផ្សេងទេ បានឆ្លងមកជាមួយអ្នកផ្សេង បានមកជួបពួកតាវិន នៅម្តុំគេហៅខ្តប ចេះតែមកជាមួយគ្នារហូតដល់ព្រំដែន។

ដានីៈ លឺថាតាវិន ហ្នឹងក្រោយមកមានរឿងរ៉ាវអី ហើយលឺថា តាម៉ុក អ្នកសម្លាប់?

ជនៈ តាម៉ុក គាត់បញ្ជាឲ្យកូនចៅគាត់ ឲ្យបាញ់សម្លាប់។

ដានីៈ ឆ្នាំណាហ្នឹង?

ជនៈ អត់ចាំទេ ដូចជាភ្លេចភ្លាំងអស់។

ដានីៈ កងពលគាត់នៅជាកងពល៦០៣ដដែល ឬមានការផ្លាស់ប្តូរអីនៅពេលមកតាមព្រំដែន?

ជនៈ ដូចជាអត់មានផ្លាស់ប្តូរទេ ដូចជានៅដដែល ក្រោយពីតាវិន គាត់នេះវារលាយអស់ វាបាក់បែក វាបាត់កងពលហ្នឹងបាត់។

ដានីៈ ដល់ពេលអ៊ំមកនៅខាងណាវិញ?

ជនៈ មកនៅក្នុងនេះដែរ តែកាលហ្នឹងមិនដឹងជាគេដូរកងពលឬម៉េច តែនិយាយរួមនៅក្នុងវរសេនាធំជាមួយហ្នឹងដែរ គ្រាន់តែកំលាំងវាបែកបាក់គ្នាអស់ច្រើន។

ដានីៈ ដល់ពេលកំលាំងបែកបាក់ទៅ អ៊ំមកដល់ព្រំដែនហើយ ពីណាកាន់កងពល? ហើយកងពលលេខប៉ុន្មានវិញទៅ?

ជនៈ ដល់យូរៗលែងលឺសូរអ្នកណាហៅថាកងពលប៉ុន្មានៗ ខ្ញុំវាភ្លេចទៅមិនដឹងជាគេផ្លាស់ប្តូរលេខ។

ដានីៈ ពីណាគេធ្វើប្រធានកាលហ្នឹង?

ជនៈ បន្ទាប់ពីតាវិន មក?

ដានីៈ បាទ!

ជនៈ កងពលកាលហ្នឹងអត់ពីតាវិន មក ទេមិនដឹងពីណាទេ ដូចភ្លេចអស់បាត់។

ដានី៖ តាញ៉ាន?

ជន៖ តាញ៉ន ។

ដានី៖ តាញ៉ន?

ជន៖ បាទ!

ដានី៖ តាញ៉ន គាត់នៅសៀមរាបរាល់ថ្ងៃ?

ជន៖ ហ្នឹងឯង តាញ៉ន, តាបាវ កាលជំនាន់ហ្នឹងនៅជាមួយគ្នា ។

ដានី៖ កងពល៦១៦មិនមែនទេ?

ជន៖ ៦១៦ហ្នឹងហើយ ។

ដានី៖ អ៊ំពេលដែលយើងមកដល់ព្រំដែន ។

ជន៖ អ៊ីមែន ផ្លាស់លេខមែននោះកាលហ្នឹង ខ្ញុំនិយាយរួមទៅមកនៅ៦១៦ហ្នឹងផង ក្រោយមកនៅ៦១២ ហើយបានមកកន្លែងចុងបញ្ចប់៨០២ ។

ដានី៖ អ៎! ៦១២ អ៊ំនៅដែរ?

ជន៖ បាទ!

ដានី៖ នៅ៦១៦ពីឆ្នាំណាដល់ឆ្នាំណាទៅ?

ជន៖ អត់ចាំឆ្នាំទៀត គ្រាន់តែធ្លាប់នៅ៦១៦ ។

ដានី៖ នៅមុនគេ ឬ៦១២?

ជន៖ មើល! ៦១៦នៅមុន ហើយបានមកនេះ៦១២ បានចុងក្រោយ៨០២នេះ ។

ដានី៖ ម៉េចបានយើងផ្លាស់ប្តូរកងពលច្រើនអីចឹង?

ជន៖ ខ្ញុំនៅតាមកំលាំង ចេញពី៦១៦ដោយសារកាលហ្នឹងយើងមកនៅតាមនេះ ដល់យើងមានជំងឺ គេត្រូវផ្លាស់ទៅទៀត ខ្ញុំទៅមិនរួចក៏ចូលមកនៅនេះ ។ ដល់នៅជាមួយនេះទៅក៏ក្រោយមកនេះក៏នេះទៀត ខ្ញុំទៅអត់រួចគេទៀត គេត្រូវផ្លាស់ទៅនោះទៀត ខ្ញុំនៅកន្លែងខាងនេះក៏នៅជាប់នេះទៅ ។

ដានី៖ អ៊ំនិយាយទៅពេលមកដល់ព្រំដែននៅម្តុំណាៗទៅ?

ជន៖ នៅខាងយើង គេហៅព្រះប្រឡាយ ។

ដានី៖ ជិតៗហ្នឹងទៅដល់ប្រាសាទព្រះវិហារដែរ?

ជន៖ អត់បានដល់ទេ អត់បានដល់ព្រះវិហារទេ ព្រះប្រឡាយមកចេះមក ។

ដានី៖ នៅក្រវិលៗម្តុំហ្នឹង?

ជន៖ នៅក្រវិលៗហ្នឹងឯង ។

ដានី៖ អត់ទៅណាឆ្ងាយទេ?

ជន៖ ត្រឹមយើងដាំស្រូវអត់បានហួសទៅណាណីទៀតទេ នៅត្រឹមហ្នឹង ។

ដានី៖ ព្រោះ៦១២មានមួយចំនួនទៅខាងព្រះវិហារដែរ?

ជន៖ ហ្នឹងហើយ ។

ដានី៖ ប្រាសាទព្រះវិហារ តែអ៊ំអត់ដែលទៅដល់ទេ?

ជន៖ អត់ទេ អត់បានទៅដល់ព្រះវិហារ ទន្ទឹមព្រះប្រឡាយហ្នឹង ។

ដានី៖ កាលហ្នឹងអ៊ំគ្រូនចាញ់ហ្នឹងអត់ជាដាច់ទេ?

ជន៖ គ្រុនចាញ់ដែលខ្ញុំថាគ្រុនរ៉ាំរ៉ៃនៅនោះហ្នឹង ។

ដានី៖ នៅកំពង់សោម ។

ជន៖ ៨ខែហ្នឹងឃើញថា ខ្ញុំទៅផ្ទះមើលមកវិញព្យាបាលទៀត មួយរយៈហ្នឹងដូចវាគ្រាន់វិញហើយ ដល់ហើយយើងចេញមកវារួមផ្សំតាមជីវភាពអីផង ជីវភាពយើងវានេះទៅវាច្រើនតែអត់សូវជា ខ្សោយសុខភាព ។

ដានី៖ ពេលអ៊ំនៅ៦១៦នៅខាងកងទ័ពសំរាប់នេះ ឬនៅមន្ទីរកងពលអី?

ជន៖ នៅកងទ័ពដែរ អត់នៅមន្ទីរទេ នៅតាមកង ។ ដល់៦១២នៅតាមកន្លែងវរសេនាធំ ហ្នឹងនៅតាមនេះវិញ ដល់មកនេះក៏អីចឹងដូចគ្នា ។

ដានី៖ កាលនៅ៦១២នៅជាមួយពីណាគេ?

ជន៖ កាលហ្នឹង៦១២ តាហឿន ។

ដានី៖ នៅជាមួយតាហឿន តែម្តង?

ជន៖ តែខ្ញុំអត់នៅកន្លែងមន្ទីរហ្នឹងទេ ខ្ញុំនៅតាមកងជាមួយតាតេង, តាឃិន ហ្នឹងមិនដឹងទៅណាហើយទេឥឡូវ ។

ដានី៖ តាតេង?

ជន៖ បាទ! តាតេង, តាឃិន មិនដឹងណាអស់ ។

អ្នកជិតខាង៖ ស្គាល់ពូហឿន ដែរ?

ដានី៖ ខ្ញុំធ្លាប់ទៅខាងអន្លង់វែង ខ្ញុំមើលភូគោល ជាមួយពូវណ្ណ កុសល ។

ជន៖ វណ្ណ កុសល ក៏គេធ្លាប់នៅហ្នឹងដែរ ។

ដានី៖ បាទ! ដល់ឆ្នាំណាដែលអ៊ំផ្លាស់មក៨០២ទៀត?

ជន៖ ៨០២ឆ្នាំប៉ុន្មានទេ នៅជំរំលើភ្នំ ។

ដានី៖ មកជំរំណាវិញ?

ជនៈ មកនៅយើងគេហៅលើភ្នំ គេហៅក-៧ ភ្លេចឆ្នាំអស់ ។

ដានីៈ ដល់៨០២មកនៅជាមួយតាវ៉ែន ។

ជនៈ តាឆន ស្លាប់បាត់ហើយ ។

ដានីៈ តាឆន នៅម៉ាឡៃហ្នឹង?

ជនៈ បាទ! ហ្នឹងហើយ លឺថាស្លាប់នៅកំពង់ធំ ថាស្លាប់បាត់ហើយ ព្រោះមានអ្នកយើងនេះគេទៅ ។

ដានីៈ ចុះតាវ៉ែន កងពលលេខប៉ុន្មានអីចឹង?

ជនៈ តាវ៉ែន យើងនេះ?

ដានីៈ បាទ!

ជនៈ អ៊ុង វ៉ែន?

ដានីៈ បាទ!

ជនៈ តាវ៉ែន កងពលលេខប៉ុន្មានចេះ ដូចជាអត់ចាំតាវ៉ែន ហ្នឹងទៀត ។ តាវ៉ែន ទើបតែស្គាល់គ្នាច្បាស់មកធ្វើនេះហើយ មកធ្វើក្រុមប្រឹក្សាហ្នឹង ពីមុនដូចថានិយាយរួម អ្នកធ្លាប់នៅតំបន់ហ្នឹងមែន តែដាច់ឆ្ងាយគ្នាតិច អត់ស្គាល់ទេ បើគេធ្វើមេ ចេះតែស្គាល់ ខ្មោចតាវិន ត្បិតតែនៅហ្នឹងតែខ្ញុំមិនដែលនេះ ទម្លាប់ខ្ញុំកន្លែងមេធំៗ បើគេមិនមានការងារហៅខ្ញុំមិនទៅអីចឹងមិនសូវបានស្គាល់អស់ទេ ។ តាវ៉ែន មិនដឹងនៅកងពលលេខប៉ុន្មានទេ ដូច៦០៧ បងវ៉ែន ខ្ញុំទើបមកស្គាល់ច្បាស់ធ្វើក្រុមប្រឹក្សាជាមួយគ្នា អាណត្តិមុន ។

ដានីៈ នៅជាមួយ ។

ជនៈ ៦០៧ហ្នឹងឯង ។

ដានីៈ ៦០៧នៅជាមួយតាញ៉ាន់?

ជនៈ ហ្នឹងហើយបងវ៉ែន, តាញ៉ាន់ ហ្នឹងឯង ៦០៧ កងពល៦០៧ ។

ដានីៈ តាឆន ៨០២?

ជនៈ ៨០២ ។

ដានីៈ គាត់ទៅនៅម៉ាឡៃ?

ជនៈ ក្រោយមកគាត់ទៅនៅម៉ាឡៃ ។

ដានីៈ អ៊ីខ្ញុំចង់ដឹងកន្លែងព្រំដែន តាមជួរព្រំដែនមាន១០០១, ១០០២, ១០០៣ ហូរហែរ ៨០៨ ។ អ៊ីដឹងថា១០០១ហេតុអីបានគេហៅឈ្មោះ១០០១?

ជនៈ ១០០១, ១០០២, ១០០៣ មិនដឹងគេដាក់លេខរបៀបម៉េច គ្រាន់តែដឹងថាដូចខ្ញុំនៅ ១០០៣ របៀបគេដាក់គ្រាន់តែសំគាល់តាមក៏មិនដឹង ខ្ញុំអត់សូវច្បាស់ដែរ ១០០១, ១០០២, ១០០៣ ។ ១០០១ ដូចខាងកើតបេះ ។

ដានីៈ កន្លែងណា១០០១?

ជនៈ ១០០១ដូចម្តុំទន្លេល្ពៅ ។

ដានីៈ ពីត្រឹមណាដល់ត្រឹមណា?

ជនៈ អត់ចាំ ។

ដានីៈ ចុះ១០០២ មានដែលអត់ទេ?

ជនៈ ១០០២ដូចជាអត់ទេ មើល១០០១ ។ ១០០២ដូចមានដែរ ។

ប្រពន្ធៈ ១០០២ ក្រែងយើងនៅ ។

ជនៈ នៅម្តុំគេហៅជិតជប់រុន ១០០៣មកម្តុំអន្លង់វែង ។

ដានីៈ ជប់រុន-អាងសេះឥឡូវ?

ជនៈ ហ្នឹងហើយ ម្តុំហ្នឹងហើយ ។

ដានីៈ ជប់រុននៅម្តុំអាងសេះឥឡូវហ្នឹង ឬក៏អីគេ?

ជនៈ អត់ទេ ជប់រុននៅនេះ នៅម្តុំព្រះប្រឡាយ ។

ដានីៈ ហ្នឹង១០០២?

ជនៈ បាទ! ១០០២ហ្នឹងហើយ ។

ដានីៈ អីចឹង១០០៣ពីត្រឹមណាដល់ត្រឹមណា?

ជនៈ វាមិនដឹងព្រំប្រទល់ត្រឹមណា គ្រាន់តែដឹងចំណុចមួយដូចជាកន្លែងដាំ១០០៣ ។

ដានីៈ កន្លែងហ្នឹងខ្ញុំដឹង ១០០៣ តែមិនដឹងពីដាំទៅដល់ណា ។

ជនៈ មិនដឹងព្រំត្រឹមណា ហើយក៏អត់ដឹងថាលេខយ៉ាងម៉េចដែរ ខ្ញុំអត់សូវយល់ដែរ គ្រាន់តែដាក់តំបន់ តែព្រំប្រទល់ឲ្យពិតប្រាកដត្រង់ណាអត់បានដឹង ។

ដានីៈ អ៊ំស្រីគាត់នៅខាងណាវិញ? នៅជាមួយគ្នា?

ជនៈ ស្រុកកំណើតគាត់នៅកំពង់ឆ្នាំង ។

ដានីៈ អ៊ំអត់ដែលបានធ្លាប់ចូលទៅខាងក្នុង? ទៅវៃនៅខាងក្នុង អត់ដែលទេ?

ជនៈ ទៅណា?

ដានីៈ ចូលទៅខាងក្នុង ទៅតាមសមរភូមិ?

ជនៈ អត់ទេ ឡើងមកវិញអត់ដែលទេ អត់ដែលទៅវៃទេ បើទៅតាមមន្ទីរធ្វើការងារ ។

ដានី:　　ខាងអ៊ំនេះឆ្ងាយពីខាងជាមួយតាម៉ុក ទេ?

ជន:　　ឆ្ងាយដែរ តាម៉ុក គាត់នៅអន្លង់វែង ។

ដានី:　　មានធ្លាប់ទៅប្រជុំជាមួយខាង?

ជន:　　អត់ទេ ។ តាម៉ុកៗ បើនិយាយរួមទៅលឺតែឈ្មោះដែរ មិនដែលបានឃើញ ។

ដានី:　　លឺតែឈ្មោះគាត់ អ៊ំអត់សូវបានឃើញគាត់ទេ?

ជន:　　អត់សូវបានឃើញទេ ។

ដានី:　　ក្រែងស្រុកកំណើតគាត់នៅខាងត្រាំកក់ដែរ?

ជន:　　នៅហ្នឹងដែរ តែគាត់នៅខាងត្រពាំងធំនេះអត់ដែលស្គាល់ទេ ។

ដានី:　　អត់ដែលស្គាល់ទេ?

ជន:　　អត់ទេ ខ្ញុំនៅខាងគុសឆ្ងាយពីគ្នាដែរ ។

ដានី:　　អ៊ំអត់ដែលដឹងថាគាត់មនុស្សយ៉ាងម៉េចៗទេ?

ជន:　　អត់ដឹង ។

ដានី:　　មេៗអ៊ំស្គាល់ពីណាជាងគេ? ដូចថាអ៊ំៗ?

ជន:　　មេៗបើគិតទៅវាគ្រាន់តែថានេះ តែយើងមិនបានទៅចូលជិត ដូចតាម៉ុក គាត់ធ្លាប់មក
តាមហ្នឹង ព្រោះកាលគាត់នៅគាត់មិនសូវជានេះ តាហ្នឹងគាត់ចុះដើរ រហូតដល់គាត់ពិការ ។

ដានី:　　គាត់ពិការនៅណាទៅ?

ជន:　　នៅយើងព្រះប្រឡាយ ។

ដានី:　　ពិការនៅព្រះប្រឡាយ?

ជន:　　បាទ! ជប់រុនហ្នឹងហើយ ព្រះប្រឡាយនៅក្រោម ។

ដានី:　　ខាងជប់រុន?

ជន:　　ជប់រុននៅលើ មកក្រោមគេថាព្រះប្រឡាយ ដល់ឡើងទៅលើជប់រុន ។

ដានី:　　កន្លែងចំការម្ទេស?

ជន:　　បាទ!

ដានី:　　ចំការម្ទេសហ្នឹងចំការម្ទេសថៃ?

ជន:　　ទេ ដីកាលហ្នឹងដីយើង ។

ប្រពន្ធ:　　អាត្រាក់ជាន់មីន ។

ដានី:　　នៅកន្លែងចំការម្ទេសហ្នឹង?

ជន:　　បាទ!

ដានីៈ ជាំស្វាមិនមែនទេ?

ប្រពន្ធៈ ជាំស្វានោះទេ ។

ជនៈ ជាំស្វានៅដីថៃ តែកាលហ្នឹងដូចអត់ច្បាស់ដែរ ។

ដានីៈ អ៊ឹអត់ដែលបានជួបតាម៉ុក និយាយអីជាមួយគាត់ទេ?

ជនៈ អត់ទេ ។

ដានីៈ អត់ដឹងថាអត្តចរិតគាត់យ៉ាំងម៉េចទេ?

ជនៈ អត់ទេ លឺតែគេថា តា អត់ដែលបានស្គាល់ បានជួប ។

ដានីៈ បើជាបុគ្គលលក្ខណៈអ៊ីវិញ អ៊ីចូលចិត្តតាម៉ុក អត់?

ជនៈ (សើច) ដូចពិបាកដែរ ។ ខ្ញុំលឺតាមតែគេៗធ្លាប់នៅជិតស្និត ។

ដានីៈ ដូចតាប៉ុល ពត អីអ៊ីដែលស្គាល់?

ជនៈ អត់រលីង ។

ដានីៈ ដែលស្គាល់ដឹងថាគាត់ជាមនុស្សយ៉ាំងម៉េច?

ជនៈ អត់ដែលដឹងសោះ វាមិនស្គាល់តែម្តងនិយាយរួមទៅ បើមួយសារហ្នឹងមិនងាយចេញមុខឲ្យអ្នកណានេះទេ ។

ដានីៈ តាសុន សេន អី?

ជនៈ តាសុន សេន អត់សូវបានស្គាល់ ។ ស្គាល់ដែលតែយើងមិនអាចកំណត់ថាគាត់យ៉ាំងម៉េច គ្រាន់តែស្គាល់ម្តងម្កាលដូចពេលជួប មិនជាជួបអីទេ គ្រាន់តែយើងទៅនេះទៅនោះ គ្រាន់គេប្រាប់ថាហ្នឹងតាសុន សេន ។ និយាយរួមទៅជំនាន់នោះអ្នកធំៗគេមិនងាយបានឲ្យឃើញទេ ហើយវាអត់ងាយបានអ្នកណាមកទំនាក់ទំនងឲ្យយើងទេ ។

ដានីៈ តានួន ជា, តាខៀវ សំផន?

ជនៈ ស្រេចបាត់ដល់ហ្នឹង អត់ទេ ។ ដូចខ្ញុំជំរាបអីចឹងត្រឹមថ្នាក់កងពលខ្ញុំមិនបានស្គាល់ទេ បើមានការអីយើងទៅ បើអត់ទេមិនដែលទៅចូលកន្លែងអ្នកធំ ដល់អីចឹងខ្ញុំអត់សូវ ។

ដានីៈ អ៊ឹដល់ពេលចុងក្រោយគេមានទំនាស់គ្នាផ្ទៃក្នុង ដូចខាងតាម៉ុក ខាងតាប៉ុល ពត ខាងតា ០៥, ០៦ យ៉ាំងម៉េចដែរ? ដឹងរឿងអីដែរ?

ជនៈ ខ្ញុំអត់ដឹងដែររឿងអស់ហ្នឹង ខ្ញុំអត់សូវដឹង គ្រាន់តែថាពេលដែលមួយសារដែលយើងថាគេមានផ្ទុះអាវុធនៅអន្លង់វែង ហើយកាលហ្នឹងកំលាំងមួយចំនួនទៅនោះ តែខ្ញុំអត់ទៅទេ ។

ដានីៈ ទៅហ្នឹងទៅណា?

ជនៈ គេឡើងទៅភ្នំតទៀត ។

ដានី៖ កំលាំងមួយចំនួនខាងតាម៉ុក?

ជន៖ ហើយខ្ញុំនឹកឃើញថា បើយើងនិយាយទៅតស៊ូវាយូរហើយ ហើយម្យ៉ាងបើយើងចង់និយាយវាន្វែតត្នល់ ខ្ញុំនឹកឃើញថាខ្ញុំអត់ទៅតាមទេ ខ្ញុំសុខចិត្តមកក្នុង ខាងរដ្ឋាភិបាល ។

ដានី៖ មកខាងរដ្ឋាភិបាលវិញ?

ជន៖ បាទ!

ដានី៖ មានអ្នកណាខ្លះដែលមកខាងរដ្ឋាភិបាល?

ជន៖ តែមិនបានរត់មកទេ តែអ្នកគេមកមាន តែខ្ញុំគ្រាន់តែនៅខាងនោះ ។ តែមួយសារដែលមានការផ្ទុះអាវុធ ខាងរដ្ឋាភិបាលចូលមកខ្ញុំក៏មកនេះ ។ កាលហ្នឹងខ្ញុំនៅយើងខាងជិតអន្លង់វែង ។

ដានី៖ ខាងអីគេហ្នឹង?

ជន៖ ហ្នឹងគេហៅម្តុំអូរបុស្សី ដល់ពេលកំលាំងមួយចំនួនគេបែកបាក់គ្នាឡើងទៅភ្នំចេះ ខ្ញុំក៏មកខាងទំនប់ដាច់ ។

ដានី៖ ច្រើនទេកាលហ្នឹង?

ជន៖ ច្រើន កំលាំងច្រើន ។

ដានី៖ ជាកងពល ឬជាអី?

ជន៖ វាលាយឡំគ្នាច្រើនណាស់ ដូចថាចំរុះគ្នា ។

ដានី៖ ភាគច្រើនរបស់ពីណាគេគ្រប់គ្រងដែលមក?

ជន៖ កាលហ្នឹងខ្ញុំនៅ៨០២ ។ ៨០២ហ្នឹងឯង តែ៨០២កាលហ្នឹងក៏ផ្លាស់ប្តូរមេបន្តបន្ទាប់ អត់ពីតាឆន វានៅមានអ្នកផ្សេងទៀត ។

ដានី៖ ពីណាគេ?

ជន៖ តាឌឿន ឥឡូវគាត់ស្លាប់បាត់ទៀតហើយ ។

ដានី៖ តាឌឿន?

ជន៖ តាឌឿន, តាជឿន សុទ្ធតែស្លាប់អស់ ។

ដានី៖ តាឌឿន, តាជឿន?

ជន៖ បាទ! ស្លាប់អស់អត់មានពីណានៅ ។

ដានី៖ តាឆន គាត់ទៅលិចតាំងពីអន្លង់?

ជន៖ តាឆន ទៅលិចឆ្នាំប៉ែតប៉ុន្មានទេ ។

ដានី៖ ទៅមុនគេសម្លាប់តាសុន សេន?

ជនៈ ដូចមុនហ្នឹង ។ មើលឆ្នាំ៩២ យើងចុះមកហ្នឹង ។

ជានីៈ ៩២ចុះមកដល់ណា?

ជនៈ មកពីនោះវិញ យើងមកពីមកនៅហ្នឹង ។

ជានីៈ មកពីព្រះប្រឡាយ?

ជនៈ បាទ!

ជានីៈ ខាងអីគេ?

ជនៈ មកពីខាងភ្នំ មកពី១០០៣ យើងមកនៅតាមជើងភ្នំដល់ទាហានខាងរដ្ឋាភិបាល កងទ័ពវៀតណាមយើងរត់ឡើងទៅលើទៀត អ្នកនេះទាំងអស់យើងទៅនៅជំរំលើ នៅទឹកដីថៃ ទៅធ្វើជំរំ ដល់ពេលសន្និសិទ្ធិប៉ារីសចប់ កំលាំងត្រូវចុះមកវិញអស់ហើយ ចុះមកនៅតាម

ជានីៈ ចុះមកនៅភូមិយើងតែម្តង?

ជនៈ បាទ ។

ជានីៈ នេះនៅតាំងពីឆ្នាំ៩២?

ជនៈ បាទ! ចុះពីនេះមកនៅតាម ។

ជានីៈ តាឆន ក្រែងគាត់សាច់ញាតិជាមួយតាសុន សេន ដែរ?

ជនៈ បាទ! គាត់ដូចប្អូនថ្លៃ ។

ជានីៈ ប្អូនថ្លៃតាសុន សេន?

ជនៈ អ៊ឹ!

ជានីៈ អីចឹងគាត់ទៅ?

ជនៈ ទៅលិចទៅខ្ញុំអត់ទៅ ហៅខ្ញុំទៅដែរតែខ្ញុំអត់ទៅ ខ្ញុំនៅនេះ ។

ជានីៈ គេទៅច្រើន ទៅលិច?

ជនៈ ទៅច្រើន ទាហានមួយមន្ទីរគាត់ហ្នឹង ។

ជានីៈ គាត់ទៅ គាត់មានទំនាស់អីនេះ បានគាត់ទៅលិច?

ជនៈ អត់ទេ អត់មានទំនាស់អីទេ ខាងលើគេដកឲ្យទៅហ្នឹង ។

ជានីៈ ខាងលើគេដកឲ្យទៅ?

ជនៈ បាទ! ដូចមិនមានទំនាស់អី កាលខ្ញុំនៅហ្នឹងគឺខ្ញុំនៅកំលាំងក្រោយ នៅ៨០២ដែរតែខ្ញុំអត់បាននៅកំលាំងមុខ ខ្ញុំនៅកំលាំងខាងក្រោយ ដល់ពេលហ្នឹងតាឆន គាត់ទៅកើត គេហៅឲ្យទៅនោះ ។

ជានីៈ ទៅលិចហ្នឹងទៅណា?

ផនៈ	ទៅមុំម៉ាឡៃហ្នឹងដឹង ទៅខាងភ្នំព្រឹក ខ្ញុំអត់ដឹងដែរ ខ្ញុំអត់ទៅខ្ញុំនៅនេះរហូត ។

ដានីៈ	តា០៥, ០៦ ម៉េចដែរ?

ផនៈ	០៥, ០៦ អត់ដឹងរឿងអីផង ខ្ញុំអត់ដឹង ព្រោះនៅខាងនោះផ្សេង និយាយរួមកាលហ្នឹង ដូចកងពលផ្សេង ។

ដានីៈ	កាលហ្នឹងអ៊ំគិតម៉េច ខាងតាម៉ុក គាត់ទៅតស៊ូតទៀត ហើយខាងយើងអត់ទៅ គិតខុសផ្ទុយពីគាត់យ៉ាងម៉េចខ្លះ? បើតាមយោបល់អ៊ំ?

ផនៈ	ខ្ញុំនឹកឃើញដូចខ្ញុំជិវាបមិញ នឹកឃើញថាវាឆ្អែតឆ្អល់ រឿងសង្គ្រាមវាលែងចង់ វាអស់សង្ឃឹម ហើយម្យ៉ាងយើងក៏មិនមានធនធានអី ដូចជិនាន់នោះយើងអត់មានលុយកាក់អត់ ហើយសំភារៈអីៗអត់មានអីដឹកជញ្ជូនទៅ កូនចៅឈឺ ខ្ញុំមើលទៅអត់ ខ្ញុំឈប់ទៅ មានគេទៅក៏ទៅៗ អត់មានអ្នកបង្ខំណាកើតទេ ខ្ញុំថាអត់ទៅខ្ញុំខ្ជិល ដល់ពេលរដ្ឋាភិបាលមកជិនាន់ហ្នឹងក៏ជម្លៀសទៅនៅទំនប់ដាច់យើងហ្នឹង ។ ខាងនោះគេទៅអូរបាយតាប់ខាងអន្លង់វែងហ្នឹងទៅអូរបាយតាប់ ហើយពួកខ្ញុំមកទំនប់ដាច់ កន្លែងទំនប់គេ ។

ដានីៈ	កាលហ្នឹងយើងអត់ទៅ? យើងអត់មានអារម្មណ៍មួយខ្លាចតាម៉ុក ព្រោះយើងប្រឆាំងជាមួយគាត់ គាត់ទៅយើងអត់ទៅ?

ផនៈ	មានទៅខ្លាចអី បើនេះខ្ញុំចេះតែទៅរហូត អត់មានបកក្រោយវិញទេ ខ្ញុំនឹកឃើញខ្ញុំលែងនៅរបបហ្នឹង ។

ដានីៈ	គិតអីចឹង?

ផនៈ	វាប្តូរគំនិតផ្សេងហើយ ខ្ញុំឈប់ ។

ដានីៈ	ដោយសារកាលហ្នឹងអ៊ំមានការទាក់ទងមកខាងរដ្ឋាភិបាលហើយ បានមានគំនិតថាយើង?

ផនៈ	អត់មាន អត់បានទាក់ទង ។

ដានីៈ	យើងគិតឃើញខ្លួនយើងថាយើងនឿយណាយនឹងការ?

ផនៈ	នឿយណាយនឹងការនៅនេះ ម្យ៉ាងវាព្រាត់ប្រាស់ ស្រុកក៏វាមិនបានទៅយូរហើយ ដល់អីចឹងខ្ញុំនឹកឃើញថាខ្ញុំឈប់ ។

ដានីៈ	ក្រែងកាលហ្នឹងយើងមានមេដឹកនាំយើងដែលត្រូវមកខាងរដ្ឋាភិបាល យើងមានដែរ?

ផនៈ	មានតា ។

ដានីៈ	ពីណាគេកាលហ្នឹង អ្នកដែល?

ផនៈ	កាលហ្នឹងអ្នកនៅមូលដ្ឋានខាងក្រោយ ។ តាកែវ គាត់ចូលមកមុនជាមួយតាជុំ ។

ដានីៈ	ជា កែវ?

ជនៈ បាទ! ជា កែវ ហើយនិង ជុំ ជាតិ គាត់ផ្ដាច់ខ្លួនមកមុនហើយ ។

ជានីៈ ជា កែវ និង ជុំ ជាតិ គាត់ចូលមកមុន ។

ជនៈ គាត់ចូលមកមុនតាំងពីពួកខ្ញុំអត់ទាន់នេះ ដល់ក្រោយមកដូចខ្ញុំថាម៉ិញសភាពការណ៍មានផ្ទុះអាវុធ គាត់ចុះមកតាមហ្នឹង កំលាំងពួកខ្ញុំក៏ទៅ ។

ជានីៈ ទៅជាមួយគាត់?

ជនៈ បាទ!

ជានីៈ តាកែវ គាត់នៅកងពលណាកាលមុន?

ជនៈ តាកែវ អត់ចាំទៀត កងពលប៉ុន្មានទេ តាកែវ ។

ប្រពន្ធៈ តាកែវ អ្នកនាំកំលាំង ។

ជានីៈ បាទ?

ជនៈ តាកែវ គាត់ផ្ដាច់ខ្លួនមកមុនគេជាមួយតាជុំ ។ តាកែវ នៅកងពលដូច៨០១ ។

ជានីៈ នៅជាមួយតាសារឿន (០៥)ហ្នឹង?

ជនៈ ភ្លេចបាត់ តាកែវ មិនចាំកងពលប៉ុន្មាន អត់ចាំ ខ្ញុំអត់ចាំទេ តែដឹងថាគាត់អ្នកផ្ដាច់ខ្លួនមកមុន ។

ជានីៈ អំពាក់ព័ន្ធនឹងការសម្លាប់គ្នា ដូចតាសុន សេន គាត់ស្លាប់ទាំងគ្រួសារ បើតាមយោបល់អ៊ំយ៉ាងម៉េចដែរហ្នឹង? បើតាមអ៊ំដឹង?

ជនៈ រឿងហ្នឹងដូចវាអត់បានច្បាស់ ដូចខ្ញុំថាអីចឹងយើងនៅនេះ ហើយរឿងខាងលើអត់បាននេះ ដល់ហើយបានលឺគេថា មានរឿងបញ្ហាម៉េចយើងអត់សូវយល់ដែរ អត់សូវដឹងដែរ ។

ជានីៈ តាមយោបល់អ៊ំវាយ៉ាងម៉េចមើលទៅ? យើងគិតមើលទៅ? ម៉េចចុងក្រោយតស៊ូៗទៅបែកបាក់គ្នាអីចឹង?

ជនៈ មិនដឹងយ៉ាងម៉េច ខ្ញុំចេះតែឆ្ងល់ដែរ មុនដំបូងខ្ញុំចេះតែឆ្ងល់ ពីមុនមកតស៊ូទាំងអស់គ្នា ដល់ទីចុងបញ្ចប់មិនដឹងជាមានទំនាស់អី គាត់ទៅជាសម្លាប់គ្នា ។

ជានីៈ កាលមុនយើងថាតស៊ូ យើងមកនេះតស៊ូដើម្បីទឹកដី ដើម្បីមានការឈ្លានពាន ចុងក្រោយក្រុមហ្នឹងទៅជាបែកបាក់គ្នាអស់?

ជនៈ មិនដឹងរឿងអី ដល់អីចឹងទៅអ្នកកងពលមួយចំនួនឃើញថាកំលាំង យើងនិយាយរួមថាវាបែកបាក់អស់ហើយ ក្រោមៗមិនដឹងជាមានសង្ឃឹមអីទៀត ដូចខ្ញុំថាខ្ញុំក៏កំណត់ថាខ្ញុំឈប់តាមទៀតហើយ បើថាម៉េចៗ បើថាមកអីចឹង ចេះតែមករហូតដល់ផ្ទះ ដល់សំបែង ដល់ពេលមកជួបខាងរដ្ឋាភិបាលថាមិនបាច់ទៅណាទេ យើងធ្លាប់នៅនេះក៏នៅហ្នឹងទៀតទៅ

រហូតទល់នឹងផ្តាច់ខ្លួនកាល៩៨ហ្នឹង នៅហ្នឹង បើគេបណ្តោយឲ្យទៅ ប្រុងទៅផ្ទះដែរហ្នឹង កាលហ្នឹង នឹកឃើញថាបែកផ្ទះយូរដែលហើយ ស្រណោះស្រុក ។ ទៅអីទេ ខាងនោះដី ចង្អៀត កំលាំងយើងធ្លាប់នៅហ្នឹងឲ្យនៅហ្នឹងក៏នៅហ្នឹងរហូត ។

ដានី: បើខ្ញុំធ្លាប់ទៅអន្លង់វែង គេថាក្រុមខាងតាប៉ុល ពត, ខាង០៥, ០៦ក្បត់ ដល់វៃគ្នាទៅ ចាញ់គេចាប់បាន គេយកទៅសម្លាប់មួយចំនួន ។

ជនៈ អាចមានព្រោះខាងហ្នឹងគេកៀក កន្លែងគេ ណាមួយគេជិតដាង កំលាំងគេអាចដឹង ពួកខ្ញុំ មិនដែលលឺអ្នកណា ។ ប៉ុល ពត ចេះមួយ ចុះពីរ, តាម៉ុក អីយ៉ាងម៉េចវាអត់ដែលមានទេ អត់ដែលលឺអីទេ ស្រាប់តែលឺថាបាញ់សម្លាប់ សុន សេន អ្នកខាងនោះអាចគេប្រាប់ច្រើន ជាង ។

ដានី: ពេលដែលគេចាប់ប៉ុល ពត កាត់ទោស ខាងអ៊ំនេះអត់មានប្រតិកម្មអីទេ?

ជនៈ អត់ វាមិនលឺ ហើយម្យ៉ាងវាអត់មានអ្នកណាមកប្រាប់យើងចេះមួយចុះពីរ ដល់អ៊ីចឹងតាម ប្រជាពលរដ្ឋធម្មតាគាត់ចេះតែហឺៗ គ្រាន់តែមានការដឹងឆ្ងល់ ដូចអូនឯងថាម៉ិញអ៊ីចឹង ពីមុនមកធ្លាប់តស៊ូហើយមកមានការកាប់សម្លាប់គ្នា គ្រាន់តែថាឲ្យមានពីណាមកប្រាប់វាអត់ ខាងនេះក្បត់ ខាងនោះក្បត់ ចេះចុះអីអត់មាន អត់មានពីណាណែនាំប្រាប់អត់ ។

ដានី: ដូចខាងអ៊ំពេញចិត្តដែលអត់ ពេលគេធ្វើអ៊ីចឹង?

ជនៈ ដូចថាវាពិបាកថាដែរ ដល់ពេលអ៊ីចឹងហើយមិនដឹងម៉េច យើងមិនហ៊ានមានមតិយោបល់ ថាម៉េចៗទេ ។

ដានី: ដែលអ៊ំថាយើងចូលសមាហរណកម្មជាមួយរដ្ឋាភិបាលតែម្តង ថាយើងចូលឆ្នាំណាទៅ?

ជនៈ ៩៨ ។

ដានី: ៩៨ហ្នឹងយើងចេញមុខ?

ជនៈ ថ្ងៃ៥ ខែ៦ យើងចូលសមាហរណកម្មនៅអន្លង់វែង ប្រមូលគ្នាពីនេះទៅ ហើយបានមក នៅតាមកន្លែងវិញ ។

ដានី: កន្លែងនេះយើងចាប់នៅខ្លួនឯង ឬក៏គេចែក?

ជនៈ ចាប់ខ្លួនឯង ។

ដានី: ចាប់នៅខ្លួនឯង?

ជនៈ បាទ! ពីមុនសុទ្ធតែព្រៃដូចអូនថាម៉ិញអ៊ីចឹង ។

ដានី: ហើយកាប់រានដីធ្វើស្រែ ធ្វើចំការ ខ្លួនឯងទៅ?

ជនៈ ហ្នឹងហើយកាប់ខ្លួនឯង ធ្វើចំការខ្លួនឯង ។

ដានី៖ អ៊ំបានត្រឡប់ទៅលេងស្រុកភូមិវិញឆ្នាំណាទៅ?

ជន៖ ទៅឆ្នាំ៩៩ ។

ដានី៖ ៩៩?

ជន៖ បាទ!

ដានី៖ ដែលបែកចេញពីផ្ទះហើយបានទៅឃើញផ្ទះវិញឆ្នាំ៩៩ដំបូង!

ជន៖ បាទ!

ដានី៖ ពីមុនមកមានបានទាក់ទងដឹងដំណឹងសុខទុក្ខអីយ៉ាងម៉េចៗដែលអត់?

ជន៖ វាពិបាកណាស់ ពិបាករឿងទំនាក់ទំនងគ្នា មានខ្លះគេមកតាមរយៈបងប្អូន យើងចេះតែសាកសួរ សួរគេទៅដឹង ខាងនោះចេះតែសុះស្មុងសួរដែរ តែវាអត់ដឹងដូចគ្នា វាពិបាកដែរ ។

ដានី៖ វាមិនដឹងដំណឹងថាយ៉ាងម៉េចៗ?

ជន៖ វាគ្មានទំនាក់ទំនងអីគ្នា ហើយអ្នកនៅផ្ទះនោះក៏មិនដឹងថានៅ ឬមួយស្លាប់អត់ដឹង ហើយម្ដាយខ្ញុំស្លាប់ឆ្នាំ៩២អត់ដឹងផង ខ្ញុំនៅនេះ ។ មិនមែនដូចឥឡូវណា ណានេះតិចក៏ដឹង កាលនោះអត់ដឹង ស្រាប់ដល់មានគេទៅមកដឹងថាម្ដាយស្លាប់កាលឆ្នាំ៩២ ។

ដានី៖ ដល់ឆ្នាំ៩៩បានទៅលេងឃើញផ្ទះវិញ?

ជន៖ បាទ!

ដានី៖ មានប្លែក ប្រែប្រួលអីម៉េចដែរពេលយើងទៅឃើញ?

ជន៖ ទៅដល់វា យើងឃើញប្រែប្រួលដែរ កន្លែងខ្លះយើងខានទៅយូរ យើងមើលទៅអត់ដឹងចំណាំអត់បាន គេមានផ្លូវ ។

ដានី៖ ទៅដល់រកផ្ទះឃើញតែម្ដង ឬអត់ទេ?

ជន៖ ទៅរកឃើញ ខ្ញុំនៅចំណាំបាន យើងទៅពីនេះតាមផ្លូវជាតិលេខ៣ ខ្ញុំគ្រាន់តែដឹងថាទៅដល់ហ្នឹងចុះត្រង់ណាៗ ហើយកាលនោះខ្ញុំចេញពីភ្នំពេញទៅដល់អង្គតាសោម ផ្លូវចុះត្រង់ណាៗចំណាំលែងបាន អីចឹងខ្ញុំដល់បែកគុសតែម្ដង នឹកឃើញទៅដល់បែកគុសវាច្បាស់ជាងមុនដល់ថ្នល់បែកគុសវាមានផ្លូវទៅលិច ទទួលខ្ញុំចុះថ្នល់បែកគុសវាមានគេអ្នក ពីដើមៗធ្លាប់ប្រហាក់ប្រហែលគ្នា ម៉ូតូគេជូនទៅដល់ផ្ទះ គេអ្នករត់ម៉ូតូឌុប ។ យើងសួរគេទៅថាមានអីទៅផ្ទះបងឯងមានអីទៅដល់ ម៉ូតូឌុបទៅ ។

ដានី៖ អ៊ំទៅម្នាក់ឯងទេ?

ជន៖ ខ្ញុំទៅជាមួយកូន ។

ដានីៈ អ៊ំស្រីអត់ទៅ?

ផនៈ អត់ទេ ខ្ញុំទៅម្នាក់ឯង ។

ប្រពន្ធៈ គាហ្នឹងទៅវះផង ។

ផនៈ ខ្ញុំវាមានជំងឺនេះផង ទៅដល់នោះជួបបងប្អូនគេឲ្យវះពោះ ។

ដានីៈ ខ្វន?

ផនៈ បាទ! ក្នុងនេះខ្ញុំវះដែរម្តង ខ្ញុំវះនៅពេទ្យយើងជំនាន់តាម៉ុក វះនៅអន្លង់វែងម្តង ដល់ខ្ញុំធ្វើការធ្ងន់ទៅវារើវិញ ដល់ពេលខ្ញុំទៅស្រុកក៏បងប្អូនគេសួរពីសុខភាពម៉េចៗ ក៏ខ្ញុំប្រាប់ទៅអីចឹងឥឡូវមកដល់ស្រុក មកដល់ភូមិជួបបងប្អូន ទៅវះពេទ្យតាកែវម្តងទៀត ។

ដានីៈ ឥឡូវជាដាច់ហើយ?

ផនៈ ២ដង វះ២ដង ក្រោយមកទៀត វះ២ដងវះខាងស្តាំ វះខាងស្តាំហ្នឹង២ដង វះនៅអន្លង់វែងហ្នឹងម្តង ដល់ទៅតាកែវម្តងទៀតខាងស្តាំដូចគ្នា ដល់ចុងក្រោយនេះមកខាងឆ្វេង ទៅវះនៅសំរោងចុងកាល់ យើង២០១១ អត់ដែលបាននេះផងតាំងពីហ្នឹងមកទល់ឥឡូវអត់សូវហ៊ានធ្វើអី ។

ដានីៈ បងប្អូននៅចាំ នៅស្គាល់គ្នាដែល? ពេលយើងទៅដល់ ។

ផនៈ នៅចាំអត់អីទេ ចាស់ៗជំនាន់គ្នានៅស្គាល់ បងប្អូនអត់អីទៅដល់នៅស្គាល់ គ្រាន់តែទៅដល់បងខ្ញុំមួយស្លាប់ហើយ បងបង្អស់ ។ អ៊ូ! ខ្ញុំនិយាយមិញដូចប្រឡំបងខ្ញុំអស់៣ហើយ ស្លាប់ ៣ បងៗស្រី បងទី១, បងទី២ ដល់មកឆ្នាំមុនបងទី៤ បន្ទាប់ខ្ញុំស្លាប់មួយទៀត ស្លាប់សុទ្ធតែជំងឺ ។ សព្វថ្ងៃនៅបងស្រីម្នាក់ ប្អូនម្នាក់ ប្អូនពៅ ហើយនិងខ្ញុំ ។

ដានីៈ ឥឡូវខស្សាហ៍ទៅមក ដូចថាអ៊ំខស្សាហ៍ទៅ ខាងនោះខស្សាហ៍មកលេង?

ផនៈ វាទៅម្តងម្កាលដែល មិនបានញឹកញាប់ទេ បងៗគាត់ចាស់ៗទៅ ហៅគាត់មក ជួនកាលគាត់អត់មានក៏ខ្ញុំទៅ តែសព្វថ្ងៃវាធូរមានទូរស័ព្ទគ្រាន់ទាក់ទងគ្នា អត់សូវអី ។ អ្នកណាមានបញ្ហាអីប្រាប់មកអីចឹងទៅ ។

ដានីៈ អ៊ំជីវភាពរស់នៅកាលពីសម័យតស៊ូ ការរស់នៅយ៉ាងម៉េច? ដូចថាផ្ទះសំបែង ហូបចុក ដល់ក្រោយមកពេលដែលយើងសមាហរណកម្មហើយ មានការខុសគ្នាម៉េចដែលទៅ?

ផនៈ ពីមុនមក ក្រោយមកវាមានការខុសគ្នា បើពីមុនវាមិនមានអីឲ្យដូចនេះ បើផ្ទះវិញយើងធ្វើខ្ទមតូចៗគ្រាន់ជ្រក វាចល័ត វាមិននៅនឹងបានយូរទេ ជួនកាលយើងនៅហ្នឹង តិចថាហ៊ាទៅនោះ ។ មុនដំបូងខ្ញុំមកនៅហ្នឹងចុះឆ្នាំ៩២មកនៅហ្នឹង ដល់រដ្ឋាភិបាលបុកមកទៅចេះទៀត បោលកន្លែងទៀត រួចទៅបានទាហានដកទៅវិញ រដ្ឋាភិបាលដកទៅវិញ បានមក

ហ្នឹងវិញទៀត។ ក្រោយពីផ្តាច់ខ្លួនមកជីវភាពដូចថាយើងនេះ ព្រោះយើងធ្វើខ្លួនឯងកាលនោះកំលាំងដូចនៅគ្រាន់ដែរ កាប់ឆ្ការហូបចុកខ្លួនឯង ផ្ទះទើបតែធ្វើបាន២០០១ហ្នឹងឯង។ អត់មានបានស្អីនេះទេ បានប៉ុណ្ណឹងឯង។

ដានី: ១០ឆ្នាំជាងហើយ?

ផន: បាទ! ជាង១០ឆ្នាំហើយ។

ដានី: ទាក់ទងពីជីវភាពវិញ?

ផន: ជីវភាពសព្វថ្ងៃខ្ញុំវាដូចថា វាមិនយ៉ាប់ក៏មិនយ៉ាប់ ហើយបើធូរធារពេកក៏អត់ដែរ វាល្មមហើយនៅតែ២នាក់គ្រួសារ កូនគេមានផ្ទះសំបែងអស់ទៅ។ សព្វថ្ងៃតាំងពីខ្ញុំសុខភាពអត់ស្រួល យាយក៏អត់ស្រួល អត់បានធ្វើចំការទេ បោល២-៣ឆ្នាំហើយអត់បានធ្វើអី គ្រាន់តែគាត់បានកំប៉ិកកំប៉ុកជីក្បែរផ្ទះ ខ្ញុំជាប់ការងារ។ ពីមុនខ្ញុំផ្តាច់ខ្លួនទៅ ខ្ញុំក៏គេដកពីខាងទាហាន ឲ្យទៅនៅខាងមូលដ្ឋានវិញ ទៅធ្វើការងារអង្គាធរ ធ្វើការងារស្រុក ដល់ឆ្នាំ២០០៦ខ្ញុំចូលនិវត្តន៍ទៅ ខ្ញុំថាឈប់ធ្វើអីហើយតាមមើលទៅវាកាន់តែយ៉ាប់សុខភាពពីមុនខ្ញុំលើសឈាម តែឥឡូវលែងអី ខ្ញុំថាឈប់ហើយ ដល់មួយសារ២០០៩គេជ្រើសរើសក្រុមប្រឹក្សា កាលហ្នឹងលោកវណ្ណ កុសល គាត់នៅចៅហ្វាយស្រុក មិនដឹងទៅរកណាបើសុទ្ធតែកំលាំងយើង ហៅទៅធ្វើវិញ ខ្ញុំទៅធ្វើបន្តរហូតដល់សព្វថ្ងៃ ជិតចប់អណត្តិ។

ដានី: ជិតផុតអណត្តិទៀតហើយ?

ផន: ជិតហើយ ២០១៨។ សព្វថ្ងៃយើងបានបៀវត្សន៍ខាងហ្នឹង ហើយខ្ញុំចូលនិវត្តន៍ទៅខ្ញុំមានប្រាក់សង្គមកិច្ច ប្រាក់អាត្រែតហ្នឹងខ្ញុំបានហ្នឹងផង បាននេះផង គ្រាន់តែទប់ជីវភាពទិញស្រូវគេមួយតោន ទុកហូបបាន១ឆ្នាំ។

ដានី: ប្រាក់បៀវត្សន៍បានឡើងនេះទេ?

ផន: ប្រាក់បៀវត្សន៍ ក្រុមប្រឹក្សាវាអត់នេះទេ កំណត់ប៉ុណ្ណឹងតែម្តង បើប្រាក់ខាងសង្គមកិច្ចវាឡើងដែរ ព្រោះខ្ញុំពេលដែលយើងចូលនិវត្តន៍ដំបូង បានតែ៩ម៉ឺនទេមួយខែ ឥឡូវបេះតែឡើងបន្តបន្ទាប់ ប្រាក់សន្ទស្សន៍ផង ប្រាក់ឧបត្ថម្ភផង បានឡើងរហូត។ ព្រោះកាលហ្នឹងមន្ទីរសង្គមកិច្ចថាដែរ ដូចបងឯងកាលណាមន្ត្រីរាជការឡើងគឺឡើងដូចគ្នា ទោះបីយើងចូលនិវត្តន៍ក៏ដោយ។ ពិនិត្យទៅឃើញអីចឹងមែន តាំងពីហ្នឹងគេឡើងឲ្យរហូតហ្នឹង តែទៅមុខទៀតមិនដឹងយ៉ាងម៉េច។

ដានី: កាលពីមុនផ្តាច់ខ្លួនជីវភាពយ៉ាងម៉េចដែរ?

ជនៈ ជីវភាពដូចខ្ញុំជិរាបខាងដើមអីចឹង វាអត់មានអីទេ ថាខ្វះទៅដូចមិនខ្វះអីដែរ និយាយរួម គ្រប់គ្រាន់ទប់ទល់ ។

ដានីៈ មានសល់មានអី?

ជនៈ អត់បានទេ ។

ដានីៈ ឧបមាថាកាលជំនាន់ហ្នឹងយើងមានរបប?

ជនៈ កាលដែលដំបូងមានរបប កាលនៅជំនាន់នោះរបបគេចែកឲ្យជាប់ របបអង្ករ ដល់ពេលក្រោយមក ដូចខ្ញុំថាចុះមកវិញហ្នឹងគេលែងមានរបបហើយ យើងធ្វើហូបខ្លួនយើង កាប់ចំការ ធ្វើស្រែ ធ្វើស្រូវហូបខ្លួនឯង កាលពីមុនរបប ។

ដានីៈ របបហ្នឹងយើងអត់មានសល់អីទេ? យើងបានហូបគ្រប់គ្រាន់?

ជនៈ បានហូប អង្ករបើយើងគិតទៅវាមួយថ្ងៃគេឲ្យ២កំប៉ុង មួយខែ៦០កំប៉ុងក្នុងម្នាក់ មានប៉ុណ្ណឹងឯង ។

ដានីៈ អត់មានលក់ដូរអីទេ?

ជនៈ វាមានបានដោះដូរដូចកាលយើងនៅលើភ្នំអីយើងទៅផ្សារថៃ យើងដូរជាម្ហូបហូប ដូរត្រីសាច់ ព្រោះយើងអត់មានលុយនោះ ដល់អីចឹងយើងដូរអង្ករ ។

ដានីៈ កាលហ្នឹងយើងអត់មានចាយលុយទេ?

ជនៈ អត់ទេ ។

ដានីៈ បើយើងចង់ទៅនេះ ទៅនោះ ត្រូវចាយលុយ ធ្វើម៉េចទៅ?

ជនៈ កាលនោះដូចមិនត្រូវទៅណា អត់មាន រឿងលុយកាក់អត់មានទេមួយសារហ្នឹង យើងមានតិចតួចប្រើលុយបាត ស្អីៗជំនាន់នោះមិនមានអ្នកណាលក់ដូរផង ចែកគ្នា សាច់យើងចែកគ្នាហូប ។

ដានីៈ ទាក់ទងពីមនោសញ្ចេតនា ការរាប់អានវិញ យ៉ាងម៉េចដែរ? ប្រែប្រួលយ៉ាងម៉េចដែរ កាលយើងនៅតស៊ូ យើងនៅជាមួយគ្នាអីចឹង ការរាប់អានគ្នា មនោសញ្ចេតនាអ៊ំនៅនេះជាមួយអ្នកជិតខាង ឬមនោសញ្ចេតនាបងប្អូនកាលពីសង្គ្រាមយើងអត់បានជួបគ្នា ដល់ពេលឥឡូវមនោសញ្ចេតនាអ្នកនៅអង្គភាព អ្នកដែលធ្លាប់ស្គាល់គ្នា អ្នកជិតខាង មានការប្រែប្រួលយ៉ាងម៉េច? ព្រោះកាលពីមុនយើងរស់នៅតាមអង្គភាព យើងហូបរួម មានរបប ។ ឥឡូវយើងជីវភាពឯកជន អ្នកណាធ្វើអីរកអី ហ្នឹងតាមសមត្ថភាពរៀងៗខ្លួន ។ មួយទៀតកាលពីមុនអ៊ំនៅនេះបែកបងប្អូន យើងអត់មានទូរស័ព្ទអីក៏មិនសូវបានទាក់ទង

យើងបែកគ្នា ឥឡូវពេលដែលយើងសមាហរណកម្មហើយ ធ្លាប់បានទៅលេងផ្ទះ ឥឡូវកាន់តែស្រួលមានទូរស័ព្ទទាក់ទងគ្នា មានការប្រែប្រួលខុសគ្នាយ៉ាងម៉េចវិញទៅ?

ជនៈ បើនិយាយពីការប្រែប្រួល ឃើញថាមានការប្រែប្រួលវាខុសពីមុនឆ្ងាយមែន បើពីមុនទៅក្នុងនេះចំងាយពីនេះទៅអន្លង់វែងយើងមិនដែលបានទំនាក់ទំនងគ្នា មិនដែលបានទៅ យើងនៅបាន នៅរាប់រកគ្នា រាប់អានគ្នាអ្នកធ្លាប់ស្គាល់គ្នា នៅអីចឹងដូចផ្ទះជាប់ៗគ្នាអីចឹង សួរទៅ ខ្លះគេមកសួរថាសុទ្ធតែសាច់ញាតិ តែការពិតអត់ទេ សុទ្ធតែគ្រាន់តែធ្លាប់មកនៅជាមួយគ្នាៗហ្នឹង គេមកនៅជិតគ្នាៗ បើទៅស្រុកអ្នកដែលធ្លាប់ស្គាល់គ្នា គេនៅបាត់យូរពេលយើងទៅគេមកសួរនាំៗ

ដានីៈ នៅធម្មតា?

ជនៈ នៅធម្មតា មិនថាយើងចេញពីនេះទៅ គេស្អប់ខ្ពើមយើងមិនរាប់រកអត់ទេ អ្នកដែលធ្លាប់ស្គាល់ពេលដែលឃើញយើងទៅអីចឹង គឺគេមកតែម្តងៗ គេមកចង់ជួប ចុះថាបាត់យូរស្មានតែស្លាប់បាត់ហើយ ដល់ពេលយើងនៅ មនោសញ្ចេតនាវានៅៗ មកនៅនេះទៀតសព្វថ្ងៃអ្នកដែលធ្លាប់នៅ ធ្លាប់ស្គាល់គ្នា ទោះបីមិនមែនស្រុកភូមិជាមួយគ្នាក៏នៅតែរាប់អានគ្នាអីចឹងដែរៗ និយាយរួមអ្នកដែលថានៅជិតៗយើងធ្លាប់ស្គាល់គ្នាពីដើម តែដោយឡែកអ្នកដែលនៅឆ្ងាយ ដូចអន្លង់វែងខ្ញុំមានដូចតែគ្នា គ្រាន់តែយើងមិនសូវបានទៅតែនៅតែអត់អីទេៗ

ដានីៈ អត់មានប្រែប្រួលអីទេ?

ជនៈ ហ្នឹងហើយ ជួបគ្នានៅតែស្គាល់គ្នាៗ

ដានីៈ ការរស់នៅកាលពីមុន ហើយឥឡូវ ដូចគ្នា?

ជនៈ ដូចគ្នា យើងនៅតែរាប់រកគ្នាអីចឹងឯង ព្រោះយើងដឹងថាសន្ដាមអ្នកណា បើនៅជិតៗហើយមានតែ ទោះបីដូចតាមៗនេះក៏អ្នកចំណូលដែរ អ្នកថ្មីដែរ មិនមែនសុទ្ធតែអ្នកនៅនេះទាំងអស់ទេ នៅជិតៗគ្នាយើងចេះតែរាប់អានគ្នាអីចឹងទៅៗ

ដានីៈ ទាក់ទងពីការក្មេងៗកាលពីជំនាន់អ៊ំនៅរួម នៅជាមួយគ្នាការតស៊ូ ហើយក្មេងៗឥឡូវនេះខុសគ្នាម៉េចដែរ?

ជនៈ វាខុស បើយើងនិយាយទៅវាខុសទាំងជីវភាព ហើយការរស់នៅៗ បើនិយាយជំនាន់នោះវានិយាយរឿងរៀនសូត្រ ជាក់ស្តែងដូចកូនខ្ញុំអាមួយបងអាយុសាមជាងគ្មានបានរៀនសូត្រអីនឹងគេ រៀនបានថ្នាក់ទី៣ជំនាន់នោះៗ រវល់រៀនៗខាន ដល់យើងពិនិត្យមើល

ក្មេងឥឡូវវាប្លែកខុស ខ្ញុំកូនមានចៅល្មមៗបានទៅរៀន មានការអប់រំជាប់ហូរហែរ។ ជំនាន់នោះអ្នកមានកូនចៅមិនសូវបាននៅជាមួយទេ។

ដានី៖ ទាក់ទងពីរៀនសូត្រគេឥឡូវគ្រាន់បើជាង!

ផន៖ គ្រាន់ បើនិយាយពីគ្រាន់ៗជាង។

ដានី៖ មុនអត់បានរៀនសូត្រ។

ផន៖ បើប្រៀបធៀបកាលជំនាន់ខ្ញុំរៀនគ្រាន់មែនទែន ដូចខ្ញុំថារៀនមិនបានទៅណាឆ្ងាយ សាលាឆ្ងាយ បើឥឡូវសាលាជិតៗ។

ដានី៖ ទាក់ទងរឿងអត្តចរិត ការអប់រំ ការរស់នៅក្នុងសង្គមយ៉ាងម៉េចដែរ?

ផន៖ ឥឡូវនេះ?

ដានី៖ ឥឡូវនេះ ហើយនិងកាលពីមុន កាលពីជំនាន់អ៊ំនៅតស៊ូ?

ផន៖ កាលជំនាន់នោះ ការអប់រំពីអត្តចរិត គឺអប់រំឲ្យចេះស្រឡាញ់គ្នា ចេះតែរាប់អានគ្នា ហើយតស៊ូរបៀបបង្ហាញថា ការជំនាន់ចូលដំបូងគេថាអាមេរិក ដូចជំនាន់លន់ នល់ឈ្មានពាន ហើយម្យ៉ាង ដល់ពេលមកក្រោយទៀតក៏គេថា ដូចជំនាន់ខ្ញុំមកនៅខាងខ្មែរក្រហមក៏ថាអីចឹងដែរ គេថាយួន ណែនាំអប់រំយើងអីចឹង។ ដល់មកឥឡូវទៀតអត់មានអីទេ ខ្ញុំអប់រំកូនចៅខំប្រឹងរកស៊ីធ្វើអំពើល្អ។

ដានី៖ ទាក់ទងរបៀបទំនៀមទំលាប់ប្រពៃណីវិញអ៊ំ ដូចថាការប្រតិបត្តិអីតាមសាសនា តាមប្រពៃណីបុណ្យទាន បើប្រៀបធៀបការពីសម័យអ៊ំចេញពីផ្ទះមក យើងចាប់ផ្តើមរស់នៅរួម ហើយសម័យសង្គ្រាម ហើយសម័យយើងតស៊ូ ការប្រតិបត្តិដូចខ្ញុំនិយាយម៉ិញទាក់ទងពីរឿងសាសនា ទាក់ទងរឿងប្រពៃណី ទំនៀមទំលាប់ បុណ្យទាន ក្រោយមកដល់ឥឡូវនេះ យើងសមាហរណកម្មមកនៅជាមួយរដ្ឋាភិបាលហើយ។ ប្រពៃណី បុណ្យទានប្រតិបត្តិសាសនាហ្នឹងវាខុសគ្នាយ៉ាងម៉េចដែរ?

ផន៖ ខុស ខុសពីមុនយើងមិនសូវបាន ដូចថារឿងបុណ្យទាន ខ្ញុំនិយាយជំនាន់នោះ មុនផ្តាច់ខ្លួនអត់ដែលមានទេ មានត្រឹមតែធ្វើបុណ្យខ្មោចអត់លោកទៀត ចាស់ៗហ្នឹងទៅ ចាស់ៗណាគាត់ចេះចាំ អញ្ជើញគាត់មកធ្វើពិធីបុណ្យ។ បើប្រពៃណីខ្ញុំអត់ដែលចោលទេ ភ្ជុំ ចូលឆ្នាំ ទោះបីយើងនៅព្រៃខុះខាតក៏នៅទំនៀមទំលាប់ជាប់ សែនភ្ជុំ ទោះបីនៅព្រៃយើងមិនមានអីធំដុំក៏ខ្ញុំនៅតែគោរពរហូត ដល់មកឥឡូវនេះរិតតែទៀតហើយខ្ញុំអត់មានបញ្ហាអីទេ។

ដានី៖ ចុះពីជំនាន់ហ្នឹងយើងភ្ជុំទៅណាទៅ? អត់មានវត្តទេ?

ជន៖ អត់មានវត្តទេ យើងធ្វើតែពេលសែន ឧទាហរណ៍ចាប់ពីថ្ងៃ១រោចមកយើងគ្រាន់តែដឹងថ្ងៃ១រោចនេះគេបិណ្ឌ១ តែយើងមិនដឹងថាធ្វើអីទៅណាអត់មានទេ គ្រាន់តែថ្ងៃខែដាច់១៥រោច វេចអន្សម ដូចយើងនេះអីចឹង វេចនំអន្សមគ្រាន់តែអត់មានលោកទេ អីចឹងមានចាស់ៗណានៅ យើងយកនំទៅជូនគាត់ ល្ងាចឡើងហៅចាស់មកសែនអីតាមទំនៀមទំលាប់យើង ។

ដានី៖ ហ្នឹងអ្នខ្លះធ្វើ អ្នកខ្លះមិនធ្វើ ឬធ្វើទូទៅ?

ជន៖ អាចអីចឹងដែរតាមមើល ខ្ញុំមិនកំណត់ថាធ្វើទាំងអស់ទេ ព្រោះអាចមានអ្នកខ្លះគេអត់នេះអ្នកខ្លះគេអត់ ។

ដានី៖ ខាងមេៗ ខាងប្រធាន គេអត់មានមកលើកទឹកចិត្ត ឬក៏ហាមឃាត់យើងអត់ឲ្យធ្វើទេ?

ជន៖ អត់ទេ មេៗក៏អាចធ្វើដែរ ។ អត់ទេ អត់មានហាមឃាត់អីទេ ។

ដានី៖ ដូចតាប៉ុល ពត គាត់អត់មានដែលប្រាប់មកប្រជាជនថាម៉េចទេ?

ជន៖ អត់ទេ អត់មានរឿងណែនាំថាឥឡូវដល់រដូវ អត់ ។ តែយើងនៅនឹកឃើញប្រពៃណីយើងពីដើមមកចេះតែធ្វើ ។

ដានី៖ កាលហ្នឹងយើងអត់មានលោកទេ?

ជន៖ អត់ ។

ដានី៖ អាចារ្យអីក៏អត់ដែរ?

ជន៖ ចាស់ៗ ។

ដានី៖ ដល់ពេលអីចឹងកាលហ្នឹងគេអត់សង្កត់ធ្ងន់ គេមិនថាធ្វើ មិនធ្វើស្រេចតែយើងទេ? គេគាំទ្រក៏មិនគាំទ្រ ប្រឆាំងក៏មិនប្រឆាំង?

ជន៖ អត់ទេ យើងធ្វើតាមតែផ្ទះយើង តែខ្ញុំពិនិត្យមើលភាគច្រើនដែរ ដល់ពេលទៅភ្ជុំ បងប្អូនគេនៅតែគោរពប្រពៃណី តែថាឲ្យមានគេណែនាំមកអីអត់ទេ ។

ដានី៖ ដល់ពេលយើងផ្ដាច់ខ្លួនហើយ ពី៩៨មក?

ជន៖ យើងមានលទ្ធភាព យើងមានពេលវេលាធ្វើគ្រប់សព្វទាំងអស់ តាំងពីចូលឆ្នាំ ភ្ជុំបិណ្ឌ រហូតបុណ្យផ្កា បុណ្យកឋិន ។

ដានី៖ វត្តយើងចាប់ផ្ដើមមាននៅក្នុងមូលដ្ឋានភូមិ-ឃុំយើង?

ជន៖ មាន នេះវត្តមួយ ។

ដានី៖ កសាងពីឆ្នាំណា?

ជន៖ ឆ្នាំប៉ុន្មានម៉ែចាំទេ?

ប្រពន្ធៈ វត្តហ្នឹងតាំងពីចាប់ផ្ដើមផ្ដាច់ខ្លួនមក ។

ជនៈ ចេះតែនាំគ្នាកសាង ព្រោះមានប្រាសាទនៅហ្នឹង មានប្រាសាទបុរាណនៅហ្នឹង យើងចេះតែនាំគ្នាមានចាស់ៗបបួលគ្នាទៅ ។

ដានីៈ មានលោក?

ជនៈ មាន ។

ដានីៈ លោកយើងបំបួសលោកនៅហ្នឹង?

ជនៈ លោកមកពីនោះ ។

ដានីៈ លោកមកពីក្នុង?

ជនៈ មកពីក្នុង ដល់មកបានចេះតែបួសបន្តៗទៅ ។

ដានីៈ ឥឡូវបានប៉ុន្មានអង្គហើយ?

ជនៈ ឥឡូវនេះលោកចេះតែចេញ-ចូលៗដែរ ចេញវស្សាទៅរៀន ។ វត្តក៏ច្រើនដែលតាមមើល ខ្ញុំមិនសូវចាំ ។

ដានីៈ អ៊ំប្រតិបត្តិតាមព្រះពុទ្ធសាសនា?

ជនៈ បាទ! ព្រះពុទ្ធសាសនា ។

ដានីៈ យើងហូរហែរមក?

ជនៈ បាទ ។

ដានីៈ តែកាលសម័យយើងធ្វើកងទ័ព ដែលនឹកនាទេ?

ជនៈ នឹក ឪពុកខ្ញុំប្រាប់ ពេលមានអាសន្នចេះតែនឹក ឲ្យចេញជារូបភាពជាក់ស្ដែងវាអត់មានកន្លែងអី រឿងនឹកចេះតែនឹក ។

ដានីៈ ដូចបងប្អូនប្រជាពលរដ្ឋយើងនៅនេះ មានគេប្រតិបត្តិសាសនាផ្សេងក្រៅពីព្រះពុទ្ធដែលអត់ទេ? ដូចអ្នកអតីតធ្លាប់តស៊ូអីដូចអ៊ំ?

ជនៈ ដូចអត់មាន ។ ឃើញមានអ្នកគេមកខាងយេស៊ូ តែមិនឃើញមានអ្នកណាចូល ។

ដានីៈ អត់មានអ្នកចូល?

ជនៈ បាទ!

ដានីៈ ប្រជាពលរដ្ឋយើងទាំងអស់គ្នាសស្រាក់សស្រាំ ដូចថាជឿលើព្រះពុទ្ធសាសនា ទៅបុណ្យទានច្រើនដែល ឬតែមួយចំនួនទេ?

ជនៈ ច្រើន ភាគច្រើន ព្រោះអីវត្តហ្នឹងពេលភ្ជុំម្តងៗ បើថានេះទៅ គ្រាន់តែថាចេះតម្រូវបើគេប្រគេនចង្ហាន់ ឬរាប់បាត្រហើយគេមកវិញ បើនៅទាំងអស់រកកន្លែងដាក់មិនបានទេមនុស្សទោះបីវត្តច្រើនមែន តែមកកន្លែងនេះវាមូលគ្នា ។

ដានី: ពេលកសាងវត្ត ឬធ្វើអីយើងឯកភាពទាំងអស់គ្នា ឬមួយចំនួនគេមិនឯកភាព ឯកភាពតែមួយចំនួន?

ជនៈ ភាគច្រើនគេឯកភាព តម្រូវរឿងកសាងវត្ត ដូចបុណ្យផ្កា បុណ្យកឋិនៗ តម្រូវកសាងវិហារជិតហើយដែរវត្ត ។

ដានី: អ៊ំការគាំងពីឆ្នាំណា ការជាមួយអ៊ំស្រី?

ជនៈ តាំងពីជំនាន់យើង៨០ ។

ដានី: ជួបគ្នាពីអង្កាល់?

ជនៈ ជួបគ្នានៅលើកាលទៅនៅភ្នំ ។

ដានី: ព្រោះអ៊ំស្រីអ្នកកំពង់ឆ្នាំង អ៊ំអ្នកតាកែវ?

ជនៈ បាទ!

ដានី: អីចឹងមកជួបគ្នាពេលដែលអ៊ំរត់មកពីខាងបូព៌ាមក?

ជនៈ ហ្នឹងហើយ តាំងពីនៅខាងក្រោមនេះនៅឡើយ ការជាមួយគ្នាមិនមានអីធំដុំ ។

ដានី: ពេលមកជួបគ្នានៅកងពល៦១៦ ឬអត់ទេ? តាំងពីជំនាន់នៅកងពលតាវិន?

ជនៈ ៦១៦ ។ អេ៎! ជួបតាំងពីនៅជាមួយតាវិន ។ អេ៎! តាវិន ងាប់ហើយ ។

ដានី: អីចឹងអ៊ំការឆ្នាំ៨០ ?

ជនៈ បាទ!

ដានី: អ៊ំស្រីគាត់ឈ្មោះអីដែរ?

ជនៈ សួស រិទ្ធិ ។

ដានី: អ៊ំស្រីអាយុប៉ុន្មានហើយ?

ជនៈ ៦៣ ។

ដានី: ដំណាលគ្នាអីចឹង?

ជនៈ គាត់ប្អូនមួយឆ្នាំ ខ្ញុំខាល គាត់ថោះ ។

ដានី: អ៊ំស្រីនៅខាងកំពង់ឆ្នាំង នៅខាងភូមិ-ឃុំអីដែរ?

ប្រពន្ធៈ ភូមិទួលឃ្លាំង ឃុំព្រៃជ្រៅ ស្រុកទឹកផុស ខេត្តកំពង់ឆ្នាំង ។ និយាយទៅមកនៅជិតអមលាំងវិញ ។ ស្គាល់អមលាំងអត់?

ដានី៖ ស្គាល់ ។

ប្រពន្ធ៖ ព្រំប្រទល់ស៊ីង ។

ដានី៖ អមលាំង កំពង់ស្ពឺ ។

ប្រពន្ធ៖ ដីកំពង់ឆ្នាំង ។

ដានី៖ តែខាងហ្នឹងស្រុកសាមគ្គីមានជ័យទេ ជាប់សាមគ្គីមានជ័យ ។

ផន៖ ក្រោយមកមិនដឹង ។

ដានី៖ អ៊ំមានកូនចៅប៉ុន្មាននាក់ដែរ?

ផន៖ កូន៣នាក់ ។

ដានី៖ ធំៗអស់ហើយ?

ផន៖ បែកអស់ហើយ ។

ដានី៖ មានគ្រួសារអស់ហើយ?

ផន៖ មានអស់ហើយ ។ អាមួយនោះបានប្រពន្ធនៅកំពង់ស្ពឺ ។

ដានី៖ បងគេ?

ផន៖ ពៅ ។ បងគេនៅខាងឈូកស ខាងជើង ។

ដានី៖ កូន៣នាក់ ប្រុសប៉ុន្មាន ស្រីប៉ុន្មាន?

ផន៖ ស្រីមួយ កូន ។ ខ្ញុំមាននេះព្រោះ គ្រួសារខ្ញុំគាត់មានប្ដីគាត់មុន បានកូនមួយសព្វថ្ងៃនៅជិតគ្នា ហើយខ្ញុំបានកូន៣តែស្លាប់មួយដែរ បានប្រុស២ ស្រី១ តែស្លាប់ស្រីបាត់ហើយ នៅសល់តែ២ឥឡូវ ។

ដានី៖ នៅសល់ប្រុស២?

ផន៖ ប្រុស២ ។

ដានី៖ ប្រុសនៅណាឥឡូវ?

ផន៖ នេះមួយនៅឈូកស ។

ដានី៖ ឈូកសគាត់មានប្រពន្ធហើយ?

ផន៖ មានហើយបានកូន២ ។ អាមួយពៅប្រពន្ធនៅកំពង់ស្ពឺបានកូនមួយ ។

ដានី៖ បានទៅឆ្ងាយ ទៅជួបគ្នាណា?

ផន៖ វាទៅការមិត្តភក្តិគេឃើញនោះ បើយើងនិយាយទៅគួរគេ បើឃើញគេស្រឡាញ់គ្នា ។

ដានី៖ ឆ្ងាយដែរ?

ផន៖ ឆ្ងាយ ។

ដានី៖ ទាល់មកលេងយាយ ។

ផន៖ រហូតបានទៅការគ្មានហៅបងប្អូនណាទៅគ្នាច្រើន បើវាឆ្ងាយ បានទៅតែបងប្អូន ។

ដានី៖ គាត់ខស្សាហ៍មកលេងទេ?

ផន៖ ទៅមកជាប់ដែរ ទើបទៅវិញកាលហើយភ្ជុំ ប្រពន្ធកូនគេមក ។

ដានី៖ អ៊ំភូមិនេះភូមិអីគេ?

ផន៖ ភូមិត្រពាំងប្រាសាទ ឃុំត្រពាំងប្រាសាទ ស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ ។

ដានី៖ អ៊ីចឹងអ៊ំខ្ញុំដូចជាអស់មានអីត្រូវសួរនាំអ៊ំទៀតហើយ អ៊ំមានអីចង់បញ្ជាក់បន្ថែមទៀតទេ ។

ផន៖ ដូចជាអត់មានអី ។

ដានី៖ អ៊ីចឹងខ្ញុំអរគុណអ៊ំច្រើនដែលចំណាយពេលប្រហែលជាជិត២ម៉ោង ដែលផ្តល់ឲ្យខ្ញុំសួរនាំទាក់ទងពីបទពិសោធន៍ជីវិតរបស់អ៊ំ ។ ខ្ញុំអរគុណអ៊ំច្រើន ។

ផន៖ បាទ!

ចប់